1546
สายด่วนเพื่อผู้ใช้แรงงาน

# ឯកសារជំនួយចំណេះដឹង
# ស្តីពីការគ្រប់គ្រងពលករ

## คู่มือส่งเสริมความรู้เกี่ยวกับการคุ้มครองแรงงาน



នាយកដ្ឋានសុខមាលភាពនិងគ្រប់គ្រងពលករ
ផ្លូវមិត្តម័យត្រី ខណ្ឌដិនដែង សង្កាត់ដិនដែង ក្រុងបាងកក 10400
ទូរស័ព្ទលេខ 0 2245 4310-4

នាយកដ្ឋានសុខមាលភាពនិងគ្រប់គ្រងពលករ

# ឯកសារជំនួយចំណេះដឹង

# ស្តីពីការគ្រប់គ្រងពលករ

(คู่มือส่งเสริมความรู้เกี่ยวกับ

การคุ้มครองแรงงาน)

# បុព្វកថា

នាយកដ្ឋានសុខមាលភាពនិងគ្រប់គ្រងពលករ មានភារកិច្ចក្នុងការមើលការខុសត្រូវពលករឲ្យបាន ទទួលសិទ្ធិតាមមាត្រដ្ឋានការងារ ដើម្បីឲ្យពលករបានទទួលសិទ្ធិប្រយោជន៍មិនតិចជាងច្បាប់កំណត់ មានសុវត្ថិភាពនៃការងារ បានទទួលសុខមាលភាពល្អដែលផ្តល់ឲ្យការងារមានជំហររឹងមាំ មានជីវភាពល្អប្រសើរ អាច ផលិតនូវផលិតផលដែលមានគុណភាពនិងនាំមកនូវភាពសន្តិសុខក្នុងសង្គម រហូតដល់មានការអភិវឌ្ឍនប្រព័ន្ធសេដ្ឋកិច្ចឈានមុខយ៉ាងរឹងមាំ ដូចនេះ ពេលពលករឈានចូលក្នុងការជួល ពលកម្មក៏និងបានទទួលការគ្រប់គ្រងសិទ្ធិ ដោយស្មើរភាព និងសមភាពគ្នា ដោយមិនរើសអើងក្នុងការប្រតិបត្ត ហើយបើកឱកាសអោយបានដឹងសិទ្ធិនិងយល់អំពីសេវាកម្មផ្នែកច្បាប់មិនថាពលករថៃឬពលករជនបរទេស

នាយកដ្ឋានសុខមាលភាពនិងគ្រប់គ្រងពលករ បានដំណើរការរៀបរៀងឯកសារ ក្បួនតម្រា ដើម្បី ឧប្ថមគាំទ្រចំនេះដឹង និងការគ្រប់គ្រងពលករ ច្បាប់ភាសាខ្មែរ ដើម្បីផ្សប់ផ្សាយឲ្យពលករជនជាតិខ្មែរបានដឹងអំពីរ សិទ្ធិនឹងទួនាទីរបស់និយោជក (ថៅកែ) និយោជិក(កូនឈ្នួល) ដែលគប្បីប្រតិបត្តិរវាងគ្នាតាមផ្លូវច្បាប់ដោយ ទទួលបានការទទូលឧប្ថមថវិកាពី ការិយាល័យក្រុមបេឡា ដើម្បីបញ្ជូនពលករជនបរទេសចេញក្រៅរាជអាណាច័ក្រ នាយកដ្ឋាន ស្វែងរកការងារនិងមានសង្ឃឹមយ៉ាងខ្ពង់ខ្ពស់ថាឯកសារច្បាប់នេះនិងផ្តល់ប្រយោជន៍ដល់ពលករខ្មែរ និងបុគ្គលផ្សេងទៀតតទៅនូវថ្ងៃខាងមុខ

នាយកដ្ឋានសុខមាលភាពនិងគ្រប់គ្រងពលករ

ខែ កញ្ញា ឆ្នាំ 2554

**ទំនាក់ទំនងពត៏មានលំអិតៈ**

សម្រាប់ពត៏មានលំអិតស្តីពីការផ្តល់សេវា ឬការសុំពិគ្រោះយោបល់ផ្សេងៗ សូមទំនាក់ទំនង អគ្គនាយកដ្ឋានសុខុមាលភាពនិងគ្រប់គ្រងពលករ ទូរស័ព្ទលេខ 1546 ឬ www.labour.go.th ឬសាកសួរពត៏មាននៅៈ

- ការិយាល័យកណ្តាល

  អគ្គនាយកដ្ឋានសុខុមាលភាពនិងគ្រប់គ្រងពលករ ផ្លូវមិត្រមេត្រី សង្កាត់ឌិនឌែន ទីក្រុងបាងកក។

  ក្រុមការងារសុខមាលភាពនិងគ្រប់គ្រងពលករមូលដ្ឋាន 1-10

- ការិយាល័យភូមិភាគ

  អគ្គនាយកដ្ឋានសុខុមាលភាពនិងគ្រប់គ្រងពលករ គ្រប់បណ្តាខេត្តក្រុង

  - នាយកដ្ឋានសុខមាលភាពនិងគ្រប់គ្រងពលករ ខេត្តតាក 055-511-505
  - នាយកដ្ឋានសុខមាលភាពនិងគ្រប់គ្រងពលករ ខេត្តសមុត្រប្រាកាន 034-413-729-30
  - នាយកដ្ឋានសុខមាលភាពនិងគ្រប់គ្រងពលករ ខេត្តរះណង 077-826-303

# ផ្នែកគ្រប់គ្រងពលករ

## (ด้านคุ้มครองแรงงาน)

## សិទ្ធិតួនាទីរបស់និយោជក និយោជិក(ពលករ)

## ក្នុងព្រះរាជក្រឹតស្តីពីការគ្រប់គ្រងពលករ ឆ្នាំព.ស. 2541

----------------------------------

### លក្ខខ័ណ្ឌនៃការជួលពលករក្នុងប្រទេសថៃ

និយោជិកដែលមានពលករចាប់ពី1នាក់ឡើងទៅ ត្រូវប្រតិបត្តិតាមលក្ខខណ្ឌដែលបាន កំណត់ក្នុងព្រះរាជក្រឹតស្តីពីការគ្រប់គ្រងពលករ ឆ្នាំព.ស. 2541 លក្ខខ័ណ្ឌនេះត្រូវបានកែសំរួល បន្ថែមក្នុងព្រះរាជក្រឹតស្តីពីការគ្រប់គ្រងពលករច្បាប់ទី 2 ឆ្នាំព.ស. 2551 ហើយវាត្រូវបានគេប្រើ ប្រាស់ ជាក្បួនច្បាប់មូលដ្ឋានក្នុងការកំណត់គោលការណ៍នៃការជួលកំលាំងពលករ ដែលក្នុង នោះបានកំណត់នូវចំនួនថ្ងៃ ពេលវេលាធ្វើការ ថ្ងៃឈប់សម្រាក ថ្ងៃសុំច្បាប់ឈប់សម្រាក ប្រាក់ ឈ្នួលពលកម្ម ប្រាក់ឈ្នួលម៉ោងបន្ថែម ប្រាក់ឈ្នួលពលកម្មនៅថ្ងៃឈប់សម្រាក សុវត្ថិភាពក្នុង ការបំពេញការងារ ការជួលពលការនី ការជួលពលករកុមារ ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗក្នុង ករណីដែលពលករត្រូវបានគេបញ្ឈប់ពីការងារ។ និយោជកគ្រប់រូបត្រូវអនុវត្តតាមគោលការណ៍ ទាំងនេះ បើពុំដូច្នោះទេនិយោជកនឹងត្រូវប្រឈមមុខចំពោះមុខច្បាប់ទាំងទោសព្រហ្មទណ្ឌ និង រដ្ឋប្បវេណី។ ក្រៅពីការអនុវត្តតាមព្រះរាជក្រឹតស្តីពីការគ្រប់គ្រងពលករនេះ និយោជកក៏ត្រូវអនុវត្តតាមព្រះរាជក្រឹតស្តីពីទំនាក់ទំនងការងារ ឆ្នាំព.ស. 2518 ផងដែរ។ ព្រះរាជក្រឹតស្តីពីការ គ្រប់គ្រងពលករបានកំណត់ឲ្យនិយោជក និងពលករមានសិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់នៃព្រះ រាជាណាចក្រថៃ ដោយមិនប្រកាន់ពូជសាសន៍ សញ្ជាតិ សាសនានិង ភេទឡើយ។

### សិទ្ធិ និងតួនាទីរបស់និយោជក–និយោជិក(ពលករ)

#### 1.ពេលវេលាធ្វើការធម្មតា

**ការងារទូទៅ**

ការធ្វើការងារទូទៅត្រូវបានកំណត់មិនឲ្យលើស ៨ម៉ោងក្នុង1ថ្ងៃ ឬ អាស្រ័យទៅតាម យល់ព្រមរបស់ភាគីនិយោជកនិងនិយោជិក ទោះជាយ៉ាងណាក៏ដោយគឺចំនួនម៉ោងធ្វើការមិន លើស 48 ម៉ោងក្នុង1សប្តាហ៍ឡើយ។

**ការងារដែលមានសភាពគ្រោះថ្នាក់**

ការងារប្រភេទនេះមានដូចជា ការងារក្នុងរូងក្រោមដី ការងារក្រោមទឹក ការងារក្នុងរូង ភ្នំ ការងារផ្លូវក្រោមដី ការងារក្នុងអាកាសអាប់អួរ ។ល។ ការងារទាំងនេះមានភាពប្រថុយ ប្រថាននឹងគ្រោះថ្នាក់ខ្ពស់ ឬមានសភាព

ការងារមិនស្ថិតនៅក្នុងសុវត្ថិភាពការងារដែល បានកំណត់។ ដូច្នេះដើម្បីការពារសុវត្ថិភាពផ្ទាល់ខ្លួន ពលករត្រូវកំណត់ឱ្យធ្វើការ តាមធម្មតាគឺ ចំនួន 7 ម៉ោងក្នុងមួយថ្ងៃ និងមិនលើស 42 ម៉ោងក្នុង1សប្តាហ៍។

## 2.ពេលវេលាឈប់សម្រាក

- ពេលវេលាឈប់សម្រាកនៅពេលបំពេញ

ការងារប្រចាំ ត្រូវបានកំណត់មិនឱ្យលើស 1 ម៉ោងក្នុង1 ថ្ងៃ គឺឈប់សម្រាកក្រោយពេលដែលពលករធ្វើការបានចំនួន 5 ម៉ោងបន្តបន្ទាប់គ្នា។ថៅកែអាចរៀបចំមិនឱ្យមាពេលឈប់សម្រាកបាន ក្នុងករណីដែលការងារនោះមានលក្ខណៈជាការងារតម្រូវឱ្យមានការធ្វើពុំមានការផ្អាកឬជាការងារបន្ទាន់។

- មុនពេលធ្វើការម៉ោងបន្ថែម: ករណីដែល

និយោជកតម្រូវឱ្យពលករធ្វើការម៉ោង បន្ថែមចាប់ពី 2 ម៉ោងឡើងទៅ និយោជកត្រូវអនុញ្ញាតិឱ្យពលករបានឈប់សម្រាកមុនពេលធ្វើការយ៉ាងតិចបំផុតចំនួន 20នាទី។

## 3.ថ្ងៃឈប់សម្រាក

- ថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ត្រូវបាន

កំណត់មិនឱ្យតិចជាង 1 ថ្ងៃក្នុង1សប្តាហ៍ ដោយថ្ងៃឈប់សម្រាកនេះមានគម្លាតពីគ្នាមិនលើសពី 6 ថ្ងៃ។

- ថ្ងៃឈប់សម្រាកបុណ្យប្រពៃណីត្រូវបានកំ

ណត់មិនឱ្យតិចជាង 13 ថ្ងៃក្នុង1ឆ្នាំ ដោយរាប់បញ្ចូល ទាំងទិវាពលកម្មជាតិផង។ បើថ្ងៃឈប់សម្រាកបុណ្យប្រពៃណីជាតិត្រូវនឹងថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ត្រូវលើកឈប់សម្រាកបុណ្យប្រពៃណីជាតិទៅថ្ងៃបន្ទាប់។

- ថ្ងៃឈប់សម្រាកប្រចាំឆ្នាំត្រូវបានកំណត់មិន

ឱ្យតិចជាង 6 ថ្ងៃក្នុង1ឆ្នាំ សម្រាប់ ពលករណាដែលមានបទពិសោធន៍ការងារជាប់គ្នារយៈពេល1ឆ្នាំ ។ ថ្ងៃឈប់សម្រាកប្រចាំឆ្នាំនេះអាចលើកទៅបូកបន្ថែមជា មួយថ្ងៃឈប់សម្រាកប្រចាំឆ្នាំនាឆ្នាំបន្ទាប់បាន ដោយអាស្រ័យទៅលើការយល់ព្រមពីសំណាក់ និយោជកនិង និយោជិកទាំង 2 ភាគី។

## 4.ការធ្វើការបន្ថែមម៉ោង ការធ្វើការនៅថ្ងៃឈប់សម្រាក

និយោជកអាចតម្រូវឱ្យពលករធ្វើការបន្ថែមម៉ោង និងធ្វើការនៅថ្ងៃឈប់សម្រាកបាន ដោយមានការយល់ព្រមពីសំណាក់ពលករ ។ និយោជកអាចឱ្យពលករធ្វើការទៅតាមភាព ចាំបាច់ក្នុងករណីដែល សភាពការងារតម្រូវឱ្យពុំមានការផ្អាកសកម្មភាពការងារ ឬមានភាព បន្ទាន់។

ចំនួនម៉ោងសរុបការងារម៉ោងបន្ថែម ការងារនៅថ្ងៃឈប់សម្រាក និងការងារម៉ោង បន្ថែម នៅថ្ងៃឈប់សម្រាកត្រូវបានកំណត់មិនឱ្យលើស 36 ម៉ោងក្នុង 1 សប្តាហ៍។

### 5.ថ្ងៃសុំច្បាប់សម្រាក

- ថ្ងៃសុំច្បាប់សម្រាកព្យាបាលជំងឺពលករអាច

សុំច្បាប់សម្រាកព្យាបាលជំងឺទៅតាមសភាពជាក់ស្តែងនៃជំងឺ។ ការសុំច្បាប់សម្រាកចាប់ពី 3 ថ្ងៃឡើងទៅ និយោជក អាចឲ្យពលករប្រគល់លិខិតចេញដោយវេជ្ជបណ្ឌិតដល់ខ្លួន បើមិនដូច្នោះទេ ពលករត្រូវបកស្រាយនូវហេតុផលឈប់សម្រាក ឲ្យនិយោជកបានជ្រាបជា ព័ត៍មាន។

- ថ្ងៃសុំច្បាប់សម្រាកមានធុរៈពលករអាចសុំ

ច្បាប់ឈប់ សម្រាក ពេលមានធុរៈចាំបាច់ផ្ទាល់ខ្លួនបាន ដោយប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុង និងច្បាប់ការងារ។

- ថ្ងៃសុំច្បាប់សម្រាកពន្យាកំណើតការសុំ

ច្បាប់ឈប់សម្រាកដើម្បីពិនិត្យសុខភាពពន្យាកំណើតត្រូវបានអនុញ្ញាត ជាដំណាក់កាលៗ ដោយរយៈពេលឈប់សម្រាក ត្រូវបានអនុញ្ញាតិតាមការស្នើសុំ និងមានបញ្ជាក់ពីវេជ្ជបណ្ឌិត។

- ថ្ងៃសុំច្បាប់សម្រាកបេសកម្មកងទ័ពពលករ

អាចសុំច្បាប់ឈប់សម្រាកពេលមានការកោះហៅកងទ័ពដើម្បីចូលជួរត្រួតពិនិត្យជំនាញសឹក ឬត្រៀមលក្ខណៈបំពេញ បេសកកម្មផ្សេងៗ ទៅតាមក្បួនច្បាប់ របស់កងទ័ព។

- ថ្ងៃសុំច្បាប់សម្រាកលំហែរមាតុភាពពលការ

នីដែលមានគត៌អាចសុំច្បាប់ឈប់សម្រាកលំហែរមាតុភាពបានម្តងមិនឲ្យលើសពី 90 ថ្ងៃដោយរាប់បញ្ចូលទាំងថ្ងៃឈប់សម្រាកផង។

- ថ្ងៃសុំច្បាប់សម្រាកទៅបណ្តុះបណ្តាលពល

ករមានសិទ្ធិសុំច្បាប់សម្រាកដើម្បីទៅចូលរួមវគ្គបណ្តុះបណ្តាល អភិវឌ្ឍ ចំណេះដឹងដើម្បីជាប្រយោជន៏ដល់ការងារសង្គមឬ ដើម្បីពង្រឹងសមត្ថភាពជំនាញ ការងាររបស់ខ្លួនបាន ក្នុងករណីដែលវគ្គបណ្តុះបណ្តាលមានកម្មវិធីសិក្សាច្បាស់ លាស់ និងមានការប្រឡងវាស់ស្ទង់ចំណេះដឹងនិងបានទទួលស្គាល់និងអនុញ្ញាតិ ពីសំ ណាក់ស្ថាប័នចំណុះឲ្យរដ្ឋាភិបាល។

### 6.ប្រាក់ឧបត្ថម្ភ

- ប្រាក់ឈ្នួល ជាប្រាក់បាតថៃ ហើយពលករ

នឹងទទួលបានប្រាក់នេះចំនួនមិនតិច ជាងតម្លៃប្រាក់ឈ្នួលអប្បបរិមា។

- ប្រាក់ឧបត្ថម្ភថ្ងៃឈប់សម្រាកសាធារណៈ

ត្រូវបានបើកជូនពលករ ដែលក្នុងនោះ បើកជូនរួមទាំង ថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ថ្ងៃឈប់សម្រាកបុណ្យប្រពៃណី និងថ្ងៃឈប់សម្រាកលំហែរប្រចាំឆ្នាំផង។ ចំពោះពលករដែលធ្វើការងារ ហើយ តម្រូវឲ្យមានការចាយប្រាក់ឈ្នួលប្រចាំថ្ងៃ ប្រចាំម៉ោង និងតាមចំនួនលទ្ធផល ការងារ ពុំមានសិទ្ធិទទួលប្រាក់ឧបត្ថម្ភសម្រាប់ថ្ងៃឈប់សម្រាកនេះទេ។

- ប្រាក់ឧបត្ថម្ភថ្ងៃសុំឈប់សម្រាកត្រូវបានបើកជូនចំពោះ
    - ការសុំច្បាប់ឈប់សម្រាកព្យាបាលជំងឺដែលមិនលើសពី 30 ថ្ងៃក្នុង1ឆ្នាំ
    - ការសុំច្បាប់ឈប់សម្រាកទៅពិនិត្យសុខភាពឡាក់ំណើត
    - ការសុំច្បាប់ឈប់សម្រាកបេសកម្ម កងទ័ពដែលមិនលើសពី60ថ្ងៃក្នុងឆ្នាំ
    - ការសុំច្បាប់សម្រាកលំហែរមាតុភាពដែលមិនលើសពី 45 ថ្ងៃ ក្នុងពេលសម្រាលកូនម្តង

**7.ប្រាក់ឈ្នួលការងារម៉ោងបន្ថែម ប្រាក់ឈ្នួលការងារនៅឈប់សម្រាក និង ប្រាក់ឈ្នួលការងារម៉ោងបន្ថែមនៅថ្ងៃឈប់សម្រាក**

**7.1** ប្រសិនបើពលករធ្វើការលើលពីចំនួនម៉ោងធម្មតាដែលបានកំណត់ ពលករមានសិទ្ធិទទួលបានប្រាក់ឈ្នួលឧបត្ថម្ភម៉ោងបន្ថែមមិនតិចជាង **1.5** ដង នៃតម្លៃឈ្នួល ការងារប្រចាំរបស់ខ្លួន។

**7.2** ប្រសិនបើពលករធ្វើការតាមពេលវេលាធម្មតានៅថ្ងៃឈប់សម្រាក ពលករមានសិទ្ធិទទួលបានប្រាក់ឈ្នួលឧបត្ថម្ភម្តងទៀត ដូចថ្ងៃធម្មតាដែរ ដោយគិតទៅ តាមចំនួនម៉ោងដែលពលករបានធ្វើការ។ ចំពោះពលករដែលពុំបានទទួលប្រាក់ ឧបត្ថម្ភសម្រាប់ថ្ងៃឈប់សម្រាក ថៅកែត្រូវឧបត្ថម្ភថ្លៃឈ្នួលការ ងារនៅថ្ងៃឈប់សម្រាក របស់ពួកគេ ក្នុងតម្លៃមិនតិចជាង 2 ដងនៃតម្លៃឈ្នួលការងារថ្ងៃធម្មតា ឬត្រូវឧបត្ថម្ភទៅ តាមចំនួនផលិតផលដែលធ្វើបាន ចំពោះពលករដែលទទួលប្រាក់ឈ្នួលតាមចំនួន ផលិតផល។

**7.3** ប្រសិនបើពលករធ្វើការនៅថ្ងៃឈប់សម្រាកលើសពីចំនួនម៉ោងដែលពួក គេធ្វើការនៅថ្ងៃធម្មតា ពលករមានសិទ្ធិទទួលបានប្រាក់ឈ្នួលឧបត្ថម្ភម៉ោងបន្ថែមចំនួន 3 ដង នៃតម្លៃឈ្នួលប្រាក់ម៉ោងបន្ថែមធម្មតា ឬតាមចំនួនផលិតផលដែលធ្វើបាន ចំពោះពលករដែលទទួលប្រាក់ឈ្នួលតាមចំនួនផលិតផល។

**ពលករមានសិទ្ធិទទួលបានប្រាក់សំណង ក្នុងករណីដែលថៅកែបញ្ឈប់ពីការងារដោយមិនបានប្រព្រឹត្តកំហុសធ្ងន់។**

**1.** ពលករដែលបានធ្វើការជាបន្តបន្ទាប់បានចំនួន 120 ថ្ងៃ តែមិនគ្រប់ 1 ឆ្នាំមានសិទ្ធិទទួលបានប្រាក់សំណងស្មើនឹងប្រាក់ឈ្នួល 30 ថ្ងៃ។

**2.** ពលករដែលបានធ្វើការជាបន្តបន្ទាប់បានចំនួន 1 ឆ្នាំ តែមិនគ្រប់ពាឆ្នាំមានសិទ្ធិទទួលបានប្រាក់សំណងស្មើនឹងប្រាក់ឈ្នួល 90 ថ្ងៃ។

**3.** ពលករដែលបានធ្វើការជាបន្តបន្ទាប់បានចំនួន 3 ឆ្នាំ តែមិនគ្រប់ 6 ឆ្នាំមានសិទ្ធិទទួលបានប្រាក់សំណងស្មើនឹងប្រាក់ឈ្នួល 180 ថ្ងៃ។

**4.** ពលករដែលបានធ្វើការជាបន្តបន្ទាប់បានចំនួន 6 ឆ្នាំ តែមិនគ្រប់ 10 ឆ្នាំមានសិទ្ធិទទួលបានប្រាក់សំណងស្មើនឹងប្រាក់ឈ្នួល 240 ថ្ងៃ។

**5.** ពលករដែលបានធ្វើការជាបន្តបន្ទាប់ចាប់ពី 10 ឆ្នាំឡើងទៅ មានសិទ្ធិទទួលបានប្រាក់សំណងស្មើនឹងប្រាក់ឈ្នួល 300 ថ្ងៃ។

## ថៅកែមិនចាំបាច់បង់សំណងឲ្យពលករ ក្នុងករណីណាមួយដូចខាងក្រោមនេះ

**1.** ពលករសុំឈប់ពីការងារខ្លួនឯង។

**2.** ប្រព្រឹត្តបទទុច្ចរិតក្នុងការបំពេញការងារ និងប្រព្រឹត្តកំហុសផ្នែកព្រហ្មទណ្ឌលើរូបថៅកែ។

**3.** មានបំណងធ្វើឲ្យថៅកែទទួលការខូចខាត។

**4.** មិនយកចិត្តទុកដាក់ចំពោះការងារដែលជាមូលហេតុធ្វើឲ្យថៅកែទទួលការខាតបង់យ៉ាងខ្លាំង។

**5.** មិនគោរពតាមបទបញ្ជាផ្ទៃក្នុង ឬតាមការចាត់តាំងការងារ ដែលស្របតាមផ្លូវច្បាប់របស់ថៅកែ។

**6.** បោះបង់ចោលការងាររយៈពេលបីថ្ងៃជាប់គ្នា ដោយគ្មានមូលហេតុច្បាស់លាស់។

**7.** ទទួលទោសជាប់ពន្ធនាគាតាមការប្រកាសសាលក្រមរបស់តុលាការ។

**8.** ក្នុងករណីថៅកែជួលពលករក្នុងរយៈពេលកំណត់មួយ ហើយថៅកែបានបញ្ឈប់ការងារពលករក្នុងរយៈពេលនោះ ការងារប្រភេទនេះមានដូចខាងក្រោម:

**8.1** ការងារក្នុងគម្រោងដែលមិនមែនជាការងារប្រចាំឬជំនួញប្រចាំរបស់ថៅកែ ។ ក្នុងករណីនេះរយៈពេលការងារត្រូវបានកំណត់យ៉ាងច្បាស់លាស់។

**8.2** ការងារដែលមានលក្ខណៈជាការងារបណ្តោះអាសន្នក្នុងរយៈពេលខ្លី ហើយមានកំណត់ថ្ងៃបញ្ចប់ការងារ។

**8.3** ការងារតាមរដូវកាល ដែលថៅកែជួលពលករចំពោះតែក្នុងរដូវកាលនោះតែប៉ុណ្ណោះ។ ការងារប្រភេទនេះត្រូវឲ្យបញ្ចប់ក្នុងរយៈពេលមិនលើសពី 2 ឆ្នាំឡើយ ដោយថៅកែបានធ្វើកិច្ចសន្យាការងារទុកចាប់តាំងពីថ្ងៃចាប់ផ្តើមការងារ។

## ការប្រើប្រាស់ពលការនី

**1.**ហាមមិនឲ្យនិយោជកប្រើពលការនីធ្វើការងារប្រភេទដូចខាងក្រោម:

- ការងាររអណ្តូងរ៉ែ ឬការងារសំណង់ដែលតម្រូវឲ្យធ្វើនៅក្រោមដី ក្រោមទឹក ក្នុងរូងភ្នំ ក្នុងផ្លូវក្រោមដី ឬចោះភ្នំ លើកលែងតែការងាណាដែលមិនបង្កឲ្យមានគ្រោះថ្នាក់ ដល់សុខភាពរាងកាយពលការនី។

- ការងារដែលត្រូវធ្វើលើទីខ្ពស់លើសពី 10 ម៉ែត្រឡើងទៅ។

- ការងារផលិត ឬដឹកជញ្ជូនវត្ថុ សម្ភារៈងាយ

នឹងឆាបឆេះ លើកលែងតែការងារនោះ មិនបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពរាងកាយពលការនី។

- ការងារផ្សេងៗដែលបានកំណត់នៅក្នុង

ច្បាប់របស់ក្រសួងការងារ។

**2.**ហាមមិនឱ្យនិយោជកប្រើពលការនីដែលមានគត៌ធ្វើការនៅចន្លោះម៉ោង 22.00 ដល់ 6.00 ធ្វើការម៉ោងបន្ថែម ឬធ្វើការនៅថ្ងៃឈប់សម្រាក ដែលមានប្រភេទការងារដូច ខាងក្រោម:

- ការងារដែលប្រើប្រាស់គ្រឿងចក្រ ឬគ្រឿងយន្តដែលមានរំញ័រខ្លាំង។
- ការងារដឹកជញ្ជូន ឬការងារដែលត្រូវធ្វើដំណើរតាមយន្តជំនិះ។
- ការលើក ដាក់ លី សែង ទាញ ឬជញ្ជូនវត្ថុ ឧបករណ៍ធ្ងន់លើសពី 15 គីឡូក្រាម។
- ការងារលើកប៉ាល់។
- ការងារផ្សេងៗដែលកំណត់នៅក្នុងច្បាប់របស់ក្រសួងការងារ។

ក្នុងករណីដែលពលការនីមានគ៌តធ្វើការក្នុងផ្នែកគ្រប់គ្រង ផ្នែកការសិក្សា ផ្នែករដ្ឋបាល ឬ ផ្នែកគណនេយ្យ និយោជកអាចអនុញ្ញាតិឱ្យពលការនីធ្វើការម៉ោងបន្ថែមនៅថ្ងៃ ធម្មតាបានដោយធានាមិនឱ្យមានផលប៉ះពាល់ដល់សុខភាពរបស់ពលការនី។

**3.**មន្ត្រីត្រួតពិនិត្យពលករអាចចេញបទបញ្ជាឱ្យនិយោជកប្តូរពេលវេលាធ្វើការ ឬកាត់បន្ថយចំនួនម៉ោងធ្វើការរបស់ពលការនីដែលធ្វើការនៅចន្លោះម៉ោង **22.00** ដល់ **6.00** បាន ប្រសិនបើមន្ត្រីរកឃើញថាការងារនោះអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់ សុខភាព ឬបង្កអសុវត្ថិភាពដល់ពលការនី។

**4.**ក្នុងករណីផដ្ឋបណ្ឌិតបញ្ជាក់ថាពលការនីពុំអាចមានលទ្ធភាពធ្វើការងាររបស់ខ្លួន បានពលការនីដែលមានគត៌មានសិទ្ធិសុំឱ្យនិយោជកប្តូរការងារប្រចាំរបស់ខ្លួនជាបណ្តោះ អាសន្នបានមុន ឬក្រោយពេលសម្រាលកូនបាន ។

**5.**ហាមមិនឱ្យនិយោជកបញ្ឈប់ការងារពលការនីព្រោះហេតុផលពលការនីមានគត៌។

## ការប្រើប្រាស់ពលករកុមារ

**1.**ហាមមិនឱ្យនិយោជកទទួលយកពលករកុមារ ដែលមានអាយុក្រោម **15** ឆ្នាំមកធ្វើការ។

**2.**ក្នុងករណីនិយោជកទទួលយកពលករកុមារ ដែលមានអាយុក្រោម **18** ឆ្នាំមកធ្វើការ និយោជកត្រូវរាយការណ៍ជូនដល់មន្ត្រីទទួលបន្ទុកត្រួតពិនិត្យពលករឱ្យបានជ្រាបជាព័ត៌មានក្នុងកំឡុង **15** ថ្ងៃដោយរាប់ចាប់តាំងពីថ្ងៃដែលពលករនោះចាប់ផ្តើមធ្វើការ។ក្រៅពីនេះនិយោជក ត្រូវរៀបចំឯកសារ កត់ត្រាសភាពបម័បំរួល និងសុពលភាពការងារព្រមទាំងរាយការណ៍ជូន មន្ត្រីទទួលបន្ទុកឱ្យបានជ្រាបក្នុងកំឡុង **7** ថ្ងៃដោយចាប់រាប់តាំងពីពេល ដែលពលករនោះ

ឈប់ពីការងារ។ និយោជកត្រូវរៀបចំឱ្យមានពេលឈប់សម្រាកយ៉ាងតិច១ម៉ោងក្នុង 1 ថ្ងៃ ក្រោយពេលដែលពលករបាន បំពេញការងារមកហើយអស់រយៈពេល **4** ម៉ោងជាប់គ្នា។ នៅក្នុងរយៈពេលធ្វើការ **4** ម៉ោងនេះ ពលករកុមារអាចមាន ពេលឈប់សម្រាកខ្លីៗ ទៅតាម ការកំណត់របស់និយោជកបន្ថែមទៀត។

**3**.ហាមមិនឱ្យនិយោជកប្រើពលករកុមារដែលមានអាយុក្រោម **18** ឆ្នាំធ្វើការនៅ ចន្លោះម៉ោង **22.00** ដល់ **6.00** លុះត្រាមានការអនុញ្ញាត ជាលាយលក្ខណ៍អក្សរពី សំណាក់ប្រធាននាយកដ្ឋាន ក្រសួងមាន សមត្ថកិច្ច។

**4**.ហាមមិនឱ្យនិយោជកប្រើពលករកុមារដែលមានអាយុក្រោម **18** ឆ្នាំធ្វើការម៉ោង បន្ថែម ឬធ្វើការនៅ ថ្ងៃឈប់សម្រាក។

**5**.ហាមមិនឱ្យនិយោជកប្រើពលករកុមារដែលមានអាយុក្រោម **18** ឆ្នាំ ធ្វើការងារប្រភេទដូចខាង ក្រោម:

- ការងាររំលាយ ស្ពាន់ ឬដែលោហៈ
- ការងារបូមលោហៈ
- ការងារដែលទទួលរងនូវសីតុណ្ហភាពក្តៅ ត្រជាក់ រំញ័រ សម្លេងនិងពន្លឺខុសពីធម្មតា ហើយ ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដល់ពលករដូចដែលបានកំណត់ក្នុងច្បាប់ក្រ សួងការងារ។
- ការងារដែលរងផលប៉ះពាល់ពីសារធាតុគីមី និងអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់ ពលករ ដូចដែលបានកំណត់ក្នុងច្បាប់ក្រសួង។ល។

**6**.ហាមមិនឱ្យនិយោជកប្រើពលករកុមារដែលមានអាយុក្រោម 18 ឆ្នាំធ្វើការនៅក្នុងទីកន្លែងដូចខាងក្រោម:

- រោងសត្តឃាត
- កន្លែងលេងល្បែងស៊ីសង
- ទីកន្លែងផ្តល់សេវាកម្មផ្សេងៗ
- ទីកន្លែងហាមឃាត់ដែលកំណត់ក្នុងច្បាប់ក្រសួង

**7**.ហាមមិនឱ្យនិយោជកបើកប្រាក់ឈ្នួលពលករកុមារ ទៅឱ្យអ្នកផ្សេង។

**8**.ហាមមិនឱ្យនិយោជកស្នើសុំឬទទួលការធានាផ្សេងៗពីភាគីពលករដែលជាកុមារ។

**9**.ពលករដែលជាកុមារមានអាយុក្រោម **18** ឆ្នាំមានសិទ្ធិសុំឈប់សម្រាកទៅចូលរួម សិក្ខាសាលា ទទួលការបណ្តុះបណ្តាល ឬទៅបំពេញភារកិច្ចផ្សេងៗបាន ក្នុងករណីដែល វគ្គសិក្ខាសាលានិងការបណ្តុះបណ្តាលនោះត្រូវ បានរៀបចំដោយគ្រឹះស្ថានសិក្សាឬអង្គភាពរដ្ឋ ឯកជន ហើយទទួលស្គាល់ដោយអគ្គនាយកដ្ឋានមានសមត្ថកិច្ច។ ក្នុងការសុំ ឈប់សម្រាកនេះ ភាគីពលករដែលជាកុមារត្រូវជម្រាបដំណឹង និងពន្យល់ហេតុផលនៃការសុំសម្រាកជូន និយោជកឱ្យបាន

ច្បាស់លាស់។ ចំណែកនិយោជកត្រូវឧបត្ថម្ភប្រាក់ឈ្នួលថ្ងៃឈប់សម្រាក ឲ្យពលករដែលជាកុមារ ដូចថ្ងៃធ្វើការធម្មតា ប៉ុន្តែការឈប់សម្រាកបែបនេះមិនត្រូវឲ្យលើស ពី **30** ថ្ងៃក្នុង១ឆ្នាំឡើយ។

## ប្រការដែលនិយោជកត្រូវអនុវត្ត:

**1**. និយោជកដែលមានពលករចាប់ពី **10** នាក់ឡើងទៅ ត្រូវរៀបចំឲ្យមានបទបញ្ជាផ្ទៃ ក្នុងជាភាសាថៃ ដោយប្រកាសឲ្យចូលជាធរមានក្នុងកំឡុង១៥ថ្ងៃ ចាប់តាំងពីថ្ងៃទទួលយក ពលករគ្រប់ចំនួន **10** នាក់។ និយោជកត្រូវបិទផ្សាយបទបញ្ជាផ្ទៃក្នុងជាសាធារណៈ នៅទី កន្លែងដែលពលករធ្វើការ ព្រមទាំងថតចំឡងជូនអគ្គនាយកដ្ឋានគ្រប់គ្រងពលករក្នុងកំឡុង ពេល 7 ថ្ងៃ ដោយរាប់ចាប់ពីពេលបទបញ្ជាផ្ទៃក្នុងចូលជាធរមាន។ បទបញ្ជាផ្ទៃក្នុងត្រូវបាន បន្តអនុវត្តនៅកន្លែងធ្វើការទោះបីជាចំនួនពលករមានការថយចុះក្រោម 10 នាក់ក៏ដោយ។

**2**. បទបញ្ជាផ្ទៃក្នុងត្រូវបញ្ជាក់នូវបញ្ហាផ្សេងៗដូចជា ថ្ងៃធ្វើការ ពេលវេលាធ្វើការ ធម្មតា ពេលវេលាសម្រាក ថ្ងៃឈប់សម្រាកនិងគោលការណ៍ឈប់សម្រាក គោលការណ៍ ធ្វើការម៉ោងបន្ថែមនិងការធ្វើការថ្ងៃឈប់សម្រាក ថ្ងៃនិងទីកន្លែងទទួលប្រាក់ឈ្នួល ប្រាក់ ឈ្នួល ការងារម៉ោងបន្ថែម ប្រាក់ឈ្នួលការងារថ្ងៃឈប់ សម្រាក និងការងារម៉ោងបន្ថែមនៅថ្ងៃ ឈប់សម្រាក ច្បាប់សម្រាកនិងគោលការណ៍ច្បាប់សម្រាក វិន័យនិងទណ្ឌកម្មក្នុងការបំពេញការងារ ការប្តឹងនិងការសុំការពិគ្រោះយោបល់ ការបញ្ឈប់ការងារ និងប្រាក់បំណាច់ ភារកិច្ច។

**3**. រៀបចំឯកសារសំគាល់អត្តសញ្ញាណពលករ ដែលរួមមាននាម គោត្តនាម ភេទ សញ្ជាតិ ថ្ងៃ ខែ ឆ្នាំកំណើត អសយដ្ឋានបច្ចុប្បន្ន ថ្ងៃចាប់ផ្តើមការងារ តំណែងការងារ អត្រាប្រាក់ឈ្នួលនិងប្រយោជន៍ដែលទទួលបាន ព្រមទាំងថ្ងៃផុតសុពលភាពការងារ។

**4**. រៀបចំឯកសារប្រាក់ឈ្នួល ប្រាក់ឈ្នួលម៉ោងបន្ថែម ប្រាក់ឈ្នួលការងារថ្ងៃឈប់សម្រាក ប្រាក់ឈ្នួលការងារម៉ោងបន្ថែមនៅថ្ងៃឈប់សម្រាក ដែលមានបញ្ជាក់ពីពេលវេលាធ្វើការ លទ្ធផលការងារ និងទឹកប្រាក់ដែលបើកជូនពលករ ដោយមានហត្ថលេខានិងឈ្មោះអ្នកទទួលប្រាក់ផង។

## ទំនាក់ទំនងសុំការឧបត្ថម្ភពីមន្ត្រីមានសមត្ថកិច្ច

**1**. ក្នុងករណីមានការរំលោភបំពានមិនគោរពតាមច្បាប់ការងារពីសំណាក់និយោជក ពលករអាចធ្វើការតវ៉ាសុំសិទ្ធិការងាររបស់ខ្លួនបានដោយមធ្យោបាយដូចខាងក្រោម:

**1.1** ពលករប្តឹងទៅកាន់មន្ត្រីទទួលបន្ទុកត្រួតពិនិត្យពលករ។

**1.2** ពលករនាំយករឿងបណ្តឹងទៅកាន់តុលាការការងារ។

**2.** ការដាក់ពាក្យបណ្តឹងរបស់ពលករ ឬញាតិមិត្តពលករ

**2.1** ដាក់ពាក្យបណ្តឹងតាមវិធីដែលអគ្គនាយកដ្ឋានណែនាំ។

**2.2** ដាក់ពាក្យបណ្តឹងទៅកាន់មន្ត្រីទទួលបន្ទុក ត្រួតពិនិត្យពលករ នៅក្នុង តំបន់ដែលពលករធ្វើការ ឬ តំបន់ដែលនិយោជករស់នៅ ឬតំបន់ដែលពលកររស់នៅក៏បាន។

**3.** ដំណាក់កាលពិចារណាពាក្យបណ្តឹងរបស់មន្ត្រីទទួលបន្ទុកត្រួតពិនិត្យពលករ

**3.1** ជំរុញការស៊ើបអង្កេតស្វែងរកការពិតពីសំណាក់និយោជក ពលករ និងសាក្សីដទៃទៀតព្រមទាំងប្រមូលភស្តុតាងដែលទាក់ទង។

**3.2** ខណៈដែលការស៊ើបអង្កេតស្វែងរកការពិតត្រូវបានបញ្ចប់ មន្ត្រីទទួល បន្ទុកត្រូវចេញសាលក្រមឲ្យនិយោជកបង់ប្រាក់ពិន័យ ឬបដិសេធពាក្យបណ្តឹង របស់ពលករ។

**3.3** ការប្រមូលភស្តុតាងស៊ើបអង្កេតស្វែងរកការពិត និងការចេញសាលក្រម តម្រូវឲ្យបញ្ចប់សព្វគ្រប់ក្នុងកំឡុង 60 ថ្ងៃ ដោយចាប់រាប់ពីពេលទទួលពាក្យបណ្តឹងមក ពិចារណា។ ប្រសិនបើមន្ត្រីទទួលបន្ទុកមិនអាចបញ្ចប់ពាក្យបណ្តឹងក្នុងរយៈពេល 60 ថ្ងៃបាន ត្រូវស្នើសុំទៅអគ្គនាយកដ្ឋាន ឬអភិបាលខេត្តដើម្បីសុំពេលវេលាស៊ើបអង្កេតបន្ថែម ប៉ុន្តែ សំណើ ពេលវេលាស៊ើបអង្កេតនេះ មិនត្រូវឲ្យលើសពី 30 ថ្ងៃឡើយ។

## ទំនាក់ទំនងសុំជំនួយឧបត្ថម្ភពីមូលនិធិសង្គ្រោះពលករ

មូលនិធិសង្គ្រោះពលករត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹតគ្រប់គ្រងពលករ ឆ្នាំព.ស. 2541 វាជាមូលនិធិដែលទទួលបានការឧបត្ថម្ភគាំទ្រពីរដ្ឋាភិបាល ហើយមានតួនាទីជួយ ដោះស្រាយ សម្រាលការលំបាកដែលកើតឡើងចំពោះមុខរបស់ពលករដូចជា ករណី ពលករ មិនបានទទួលប្រាក់ឈ្នួលគ្រប់ដូចដែលមានចែងក្នុងព្រះរាជក្រឹតគ្រប់គ្រងពលករ ឆ្នាំព.ស. 2541 ករណីពលករត្រូវបានគេបញ្ឈប់ពីការងារ ឬគ្រោះថ្នាក់ដល់អាយុជីវិត ឬករណីដទៃ ទៀតដែលកំណត់ដោយគណៈកម្មការមូលនិធិសង្គ្រោះពលករ។

## គោលការណ៍ការឧបត្ថម្ភថវិការបស់មូលនិធិ

**1**.ថវិកាឧបត្ថម្ភក្នុងករណីនិយោជកមិនបើកប្រាក់បំណាច់ការងារជូនពលករ

- រៀបឲ្យមានការឧបត្ថម្ភក្នុងករណីដែល

មន្ត្រីត្រួតពិនិត្យពលករមានបទបញ្ជាឲ្យនិយោជកបើកប្រាក់បំណាច់ការងារជូនពលករ តែផ្ទុយទៅវិញនិយោជក បើកឲ្យមិនគ្រប់ចំនួនកំណត់ឬបើកប្រាក់មិនទៅតាមអ្វីដែលបានចែងក្នុងច្បាប់ការងារ។នៅក្នុងករណីនេះគឺតម្រូវឲ្យមានការឧបត្ថម្ភប្រាក់សង្គ្រោះដូចតទៅៈ

- ចំពោះពលករដែលបានធ្វើការ

បន្តបន្ទាប់គ្រប់ចំនួន **120** ថ្ងៃ (តែបទពិសោធន៏ការងារមិនទាន់គ្រប់៣ឆ្នាំ) ពលករនឹងទទួល ប្រាក់ ឧបត្ថម្ភចំនួន **30** ដងនៃថ្ងៃឈ្នួលអប្បបរមា ថ្ងៃធ្វើការដែលពលករ ទើប ទទួលបានតាមព្រះរាជក្រឹតគ្រប់គ្រងពលករឆ្នាំព.ស. 2541។

- ចំពោះពលករដែលបានធ្វើការបន្តបន្ទាប់

គ្រប់ចំនួន៣ឆ្នាំ (តែបទពិសោធន៏ការងារមិនទាន់គ្រប់ 10 ឆ្នាំ) ពលករនឹងទទួលប្រាក់ ឧបត្ថម្ភចំនួន 60 ដងនៃថ្ងៃឈ្នួលអប្បបរមា ថ្ងៃធ្វើការដែលពលករទើប ទទួលបានតាមព្រះរាជក្រឹតគ្រប់គ្រងពលករឆ្នាំព.ស.2541។

- ចំពោះពលករដែលបានធ្វើការបន្តបន្ទាប់

ចាប់ពី 10 ឆ្នាំឡើងទៅពលករ នឹងទទួលប្រាក់ឧបត្ថម្ភចំនួន **90** ដងនៃថ្ងៃឈ្នួលអប្បបរមាថ្ងៃធ្វើការ ដែល ពលករទើបទទួលបានតាមព្រះរាជក្រឹតគ្រប់គ្រងពលករឆ្នាំព.ស. 2541 ។

ការឧបត្ថម្ភទាំងនេះគឺមិនត្រូវឲ្យលើសពីចំនួនថវិការដែលមន្ត្រីទទួលបន្ទុកកំណត់ដោយអនុលោមតាមមាត្រាទី 124 នៃព្រះរាជក្រឹតគ្រប់គ្រងពលករឆ្នាំព.ស. 2541ហើយដែលបានធ្វើវិសោធនកម្ម(ច្បាប់ទី2)ឆ្នាំ ព.ស. 2551។

**2**. ថវិកាសង្គ្រោះសម្រាប់ករណីក្រៅពីប្រាក់បំណាច់ការងារ

- ក្រៅពីបញ្ហាប្រាក់បំណាច់ការងារ នៅ

មានបញ្ហាជាច្រើនទៀត ដូចជា បញ្ហាប្រាក់ឈ្នួលជាដើម។ ក្នុងករណីដែលនិយោជកមិនមានលទ្ធភាពបើក ប្រាក់ឈ្នួលជូនពលករតាមបទបញ្ជារបស់មន្ត្រីទទួលបន្ទុក ពលករនឹងទទួល បានការជួយឧបត្ថម្ភសង្គ្រោះ តែត្រូវទទួលបានការអនុម័តពីគណៈកម្មការមូលនិធិសង្គ្រោះពលករជាមុនសិន។

# ផ្នែកសុវត្ថិភាពនៅក្នុងការធ្វើការងារ

## (ด้านความปลอดภัยในการทำงาน)

## បទបញ្ជាផ្ទៃក្នុង១០ប្រការដើម្បីសុវត្ថិភាព អនាម័យ និងបរិស្ថានជុំវិញកន្លែងធ្វើការដែល និយោជិកត្រូវអនុវត្តន៍

**1.** និយោជិកត្រូវអនុវត្តន៍តាមបទបញ្ជាផ្ទៃក្នុង និង វិធីអនុវត្តន៍ដើម្បីសុវត្ថិភាព តាមបទបញ្ជាដែលនិយោជកបានកំនត់ និងប្រាប់អោយដឹងដើម្បីការពាឧបទ្ទេវហេតុ ផ្សេងៗក្នុងពេលបំពេញការងារ

**1.1** គួរប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុង និងវិធីអនុ វត្តន៍ដើម្បីសុវត្ថិភាពនិងចៀសវាង នូវទង្វើផ្សេងៗដែលនាំអោយអន្តរាយដល់ពលករដទៃនិងនិយោជកព្រោះទោះបីជានិយោជកបានដាក់បទបញ្ជាយ៉ាងល្អឥតខ្ចោះយ៉ាងណាក៏ដោយក៏គ្មានប្រយោជន៍ប្រសិនបើនិយោជិកមិនអនុវត្តន៍តាមដើម្បីការពាឧបទ្ទេវហេតុផ្សេងៗ ដែលអាចនិង កើតឡើងក្នុងពេលបំពេញការងារនោះ។

**1.2** សុវត្ថិភាពការងារអាចកើតឡើងបានលុះត្រា តែនិយោជិកចូលរួមជួយ អនុវត្តន៍ ទាំងអស់គ្នា។

**1.3** និយោជិកត្រូវតែចូលរួមអនុវត្តន៍តាមបទ បញ្ជាផ្ទៃក្នុង និងវិធីអនុវត្តន៍ដើម្បី សុវត្ថិភាពអោយបានពេញទំហឹង ទើបអាចចៀសផុតពីការកើតឧបទ្ទេវហេតុផ្សេងៗ ក្នុងពេលបំពេញការងារបាន។

**2.** និយោជិកមានសិទ្ធិទទួលបានការបណ្តុះបណ្តាមុននិងចេញទៅបំពេញការងារ និងស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធានក្រុមយ៉ាងហ្មត់ចត់ ដើម្បីសុវត្ថិភាពក្នុងពេលធ្វើការ។

**2.1** មុននិងអោយនិយោជិកចេញទៅបំពេញការងារ និយោជកត្រូវតែបណ្តុះបណ្តាល និយោជិក និងវិធីអនុវត្តន៍ដើម្បីសុវត្ថិភាពជាមុនសិន

**2.2** ក្នុងពេលអនុវត្តន៍ការងារនិយោជិកត្រូវទទួលបានការត្រួតពិនិត្យ ការគ្រប់គ្រង ការមើលការខុសត្រូវថាតើគេមានការត្រៀមខ្លួនដើម្បីធ្វើការហើយឬនៅ ហើយតើ បរិយាកាសជុំវិញនៅកន្លែងធ្វើការរបស់និយោជិកមានសុវត្ថិភាពគ្រប់គ្រាន់សំរាបធ្វើការហើយឬនៅ ពីសំណាក់ប្រធានក្រុម

**2.3** និយោជិកត្រូវទទួលបានការមើលការខុសត្រូវដើម្បីអោយពួកគេអាចធ្វើការបាន យ៉ាងមានសុវត្ថិភាពពីសំណាក់ប្រធានក្រុមគ្រប់ពេលវេលា

**3.** និយោជិកមានសិទ្ធិស្របច្បាប់ក្នុងការត្រួតពិនិត្យសុខភាព ការទទួលពត៍មាន និងលទ្ធផលនៃការត្រួតពិនិត្យសុខភាពតាមស្ថានភាពប្រថុយប្រថានក្នុងការងាររបស់ខ្លួន

**3.1** និយោជិកមានសិទ្ធិដឹងយ៉ាងលំអិតអំពីផលប៉ះពាល់របស់សារធាតុគីមី និងវិធីការពាររបស់វាពេលខ្លួនធ្វើការជាមួយសារធាតុគីមីទាំងនោះ

**3.2** ប្រសិនបើនិយោជិកដឹងថាកន្លែងធ្វើការរបស់ខ្លួនមានសារធាតុគីមីដែលធ្វើអោយ ប៉ះពាល់ដល់សុខភាពរបស់ខ្លួន និយោជិកអាចស្នើរអោយមានការត្រួតពិនិត្យ និងវាស់ បរិយាកាសជុំវិញកន្លែងធ្វើការ ហើយនិងការត្រួតពិនិត្យសុខភាព និងលទ្ធផលនៃការ ត្រួតពិនិត្យសុខភាពតាមស្ថានភាពប្រថុយប្រថានក្នុងការងាររបស់ខ្លួនបាន។

**4.** និយោជិកត្រូវទទួលបានសំភារះនិងឧបករណ៍ដែលសមស្របសំរាប់ធ្វើការ អោយនិយោជក

**4.1** ការងារអ្វីក៏ដោយដែលនិយោជកអោយនិយោជិកអនុវត្តន៍ទោះបីជាយល់ថាគេជា និយោជិកក៏ដោយ ក៏ត្រូវគិតថាតើវាសមស្របនិងភាពស្ទាត់ជំនាញរបស់និយោជិកហើយឬ នៅ ហើយប្រសិនបើយល់ថានិយោជិកអាចធ្វើបានក៏ត្រូវមានសំភារះ និងឧបករណ៍ផ្តល់ អោយនិយោជិកដើម្បីអនុវត្តន៍តាមការងារដែលនិយោជកដាក់អោយប្រកបដោយសុវត្ថិភាព។

**4.2** នៅពេលដែលនិយោជកផ្តល់សំភារះនិងឧបករណ៍អោយ និយោជិកត្រូវចេះ ប្រើប្រាស់សំភារះនិងឧបករណ៍ទាំងនោះអោយបានត្រឹមត្រូវទៅតាមការងាររបស់ខ្លួន និងត្រូវ ចេះថែរក្សា រៀបចំអោយមានរបៀបរៀបរយ។

**5.** និយោជិកមានសិទ្ធិទទួលបានការថែរក្សាសុវត្ថិភាព អនាម័យកន្លែងធ្វើកា និងបរិស្ថាន ជុំវិញកន្លែងធ្វើការដោយនិយោជកជាអ្នកទទួលខុសត្រូវក្នុងការចំនាយ

**5.1** និយោជកមានតួនាទីទទួលខុសត្រូវលើអនាម័យកន្លែងធ្វើការនិងបរិស្ថានជុំវិញ កន្លែងធ្វើការដើម្បីអោយនិយោជិកធ្វើការប្រកបដោយសុវត្ថិភាព។

**5.2** និយោជកជាអ្នកចំនាយទាំងអស់ទៅលើការសំអាតអនាម័យនិងបរិស្ថានជុំវិញ កន្លែងធ្វើការ។

**5.3** ប្រសិនបើនិយោជិកត្រូវការឧបករណ៍ការពារសុវត្ថិភាពផ្ទាល់ខ្លួន និយោជក ត្រូវតែរៀបចំយកមកអោយដោយការចំនាយជាបន្ទុករបស់និយោជក ហើយនិយោជកត្រូវទទួលខុសត្រូវអោយនិយោជិកបានប្រើវារហូតនៅពេលធ្វើការ។

**6.**និយោជិកមានសិទ្ធិទទួលបានកាបណ្តុះបណ្តាលដើម្បីអោយកន្លែងធ្វើការនិងបរិស្ថាន ជុំវិញកន្លែងធ្វើការប្រកបដោយសុវត្ថិភាពទៅតាមច្បាប់កំនត់

**6.1** និយោជិកមានសិទ្ធិទទួលបានការបណ្តុះបណ្តាលដោយមិនចាំបាច់ចំនាយប្រាក់ និងត្រូវយល់ថាវាជាការងារដែលខ្លួនត្រូវប្រតិបត្តិ។

**6.2** និយោជិកមានសិទ្ធិទទួលបានការហ្វឹកហ្វឺនដើម្បីអោយកន្លែងធ្វើការនិងបរិស្ថាន ជុំវិញកន្លែងធ្វើការប្រកបដោយសុវត្ថិភាពទៅតាមច្បាប់កំនត់ជារឿយៗហើយត្រូវយល់ថាវាជាការងារដែលខ្លួនត្រូវប្រតិបត្តិ។

**7.** និយោជិកមានសិទ្ធិបដិសេធនូវរាល់បញ្ជារបស់និយោជក នៅពេលដែលខ្លួនយល់ថា ការងារដែលនិយោជកបញ្ជាមកនោះវាគ្មានសុវត្ថិភាព និងអាចធ្វើអោយមានគ្រោះថ្នាក់ដល់ ខ្លួន ប្រសិនបើនិយោជកអោយនិយោជិកធ្វើការ ប្រឈមមុខនិងគ្រោះថ្នាក់ដោយមិនទទួល

ខុសត្រូវលើសុវត្ថិភាព ឬមិនមានឧបករណ៍ដើម្បីការពារសុវត្ថិភាពផ្ទាល់ខ្លួនយ៉ាងត្រឹមត្រូវ ទេនោះនិយោជិកមានសិទ្ធិបដិសេធមិនធ្វើតាមបានបើទោះបីជាការងារនោះជាបញ្ជារបស់និយោជក ឬជាតួនាទីរបស់ខ្លួនក៏ដោយ។

**8.** និយោជិកមានសិទ្ធិបញ្ចេញមតិយោបល់ទាក់ទងនិងសុវត្ថិភាព អនាម័យកន្លែងធ្វើការ និងបរិស្ថានជុំវិញកន្លែងធ្វើការ និងមានសិទ្ធិឈរឈ្មោះដើម្បីអោយនិយោជិកដ៏ទៃទៀតជ្រើស រើសធ្វើជាតំណាងក្នុងគណៈកម្មការទាក់ទងនិងសុវត្ថិភាព អនាម័យកន្លែងធ្វើការនិងបរិស្ថាន ជុំវិញកន្លែងធ្វើការ(ប្រសិនបើច្បាប់កំនត់អោយមាន)។ប្រសិនបើនិយោជិកជួបប្រទះនិងស្ថានភាពការងារដែលអាចនិងបង្កអោយមានគ្រោះថ្នាក់ក្នុងពេលបំពេញការងារនិយោជិក ត្រូវមករាយការណ៍អោយប្រធានក្រុមបានដឹង។

**9.** និយោជិកត្រូវទទួលបានថ្លៃឈ្នួល និង សុខមាលភាព សមរម្យដើម្បីអោយការរស់នៅប្រកបដោយសុខសុភមង្គល និងជំរុញអោយមានភាពគង់វង្ស សុវត្ថិភាព។

**10.** កូនឈ្នួលមិនត្រូវសំលឹងឃើញផលប្រយោជន៍ផ្សេង ដែលថៅកែផ្តល់អោយ ដើម្បី ជំនួសអោយសិទ្ធិក្នុងការទទួលបានសុវត្ថិភាព អនាម័យកន្លែងធ្វើការ និងបរិស្ថានជុំវិញកន្លែង ធ្វើការឡើយ ព្រោះវាមិនអាចផ្លាស់ប្តូរគ្នាបានទេ។

## សារៈសំខាន់របស់

## ព្រះរាជក្រឹត្យស្តីពី សុវត្ថិភាព អនាម័យ និងបរិស្ថានជុំវិញកន្លែងធ្វើការ ឆ្នាំព.ស. 2554

**1.** ព្រះរាជក្រិតស្តីពី សុវត្ថិភាព អនាម័យ និងបរិស្ថានជុំវិញកន្លែងធ្វើការ អនុក្រិតចុះថ្ងៃទី 17 ខែ មករា ឆ្នាំ 2554 និងចូលជាធរមាននៅពេលផុតកំនត់ **180** ថ្ងៃរាប់ចាប់ពីថ្ងៃប្រកាស(ថ្ងៃទី **16** កក្កដា ឆ្នាំ 2554។

**2.** មិនមែនជាកាបង្គាប់អោយមន្ត្រីថ្នាក់កណ្តាល មន្ត្រីថ្នាក់ភូមិភាគ មន្ត្រីថ្នាក់តំបន់ និងកិច្ចការផ្សេងៗដែលបានកំនត់តាមច្បាប់របស់ក្រសួង តែផ្នែករាជការ និងកិច្ចការផ្សេងៗ ត្រូវចាត់អោយមានស្តង់ដាក្នុងការគ្រប់គ្រងផ្នែកសុវត្ថិភាព មិនត្រូវអោយទាបជាងស្តង់ដា របស់ព្រះរាជក្រិត។

**3.** អត្ថន័យសំខាន់ៗរបស់ពាក្យ

សុវត្ថិភាព អនាម័យ និងបរិស្ថានជុំវិញកន្លែងធ្វើការ មានន័យថាដការប្រព្រឹត្ត ឬ សភាពការប្រតិបត្តិដែលប្រាសចាកពីឧបទ្ទេវហេតុដែលបណ្តាលអោយមានគ្រោះថ្នាក់ ដល់ជីវិត ខ្លួនប្រាណ ទឹកចិត្ត ឬ សុខភាពអនាម័យក្នុងពេលបំពេញការងារ។

និយោជក មានន័យថា និយោជកតាមច្បាប់នៃការគ្រប់គ្រងពលករ គឺសរុបរួមទាំង អ្នកប្រកបអាជីពផ្សេងៗដែលយល់ព្រមអោយបុគ្គលណាម្នាក់មកធ្វើការដើម្បីបំរើផលប្រយោជន៍អោយខ្លួន ឬ ក្នុងគ្រឹះស្ថានប្រកបអាជីវកម្ម មិនថាជាការធ្វើការក្នុងផ្នែកណាមួយឬទាំងមូល ក្នុងដំណើរការនៃការផលិតឬអាជីវកម្មដែលស្ថិតក្នុងការទទួលខុសត្រូវរបស់ម្ចាស់គ្រឹះស្ថានប្រកបអាជីវកម្ម។

និយោជិកមានន័យថា និយោជិកមច្បាប់នៃការគ្រប់គ្រងពលករ គឺរួមទាំងអ្នកដែល ទទួល បានការយល់ព្រមអោយធ្វើការក្នុងគ្រឹះស្ថានប្រកបអាជីវកម្មរបស់និយោជកមិនថា មានឈ្មោះអ្វីក៏ដោយ។

**4.** ព្រះរាជក្រិត្យមាន **8** ជំពូក ចែកជា **74** មាត្រា មានខ្លឹមសាដូចតទៅ៖

**ជំពូក 1 មេរៀនទូទៅ**

កំនត់ភារៈកិច្ចរបស់និយោជកនិងនិយោជិក ដើម្បីអោយនិយោជិកនិងគ្រឹះស្ថាន ប្រកបអាជីវកម្មមានសុវត្ថិភាព។

**ជំពូក 2 ការគ្រប់គ្រងនិងដំណើរការនៃផ្នែកសុវត្ថិភាព អនាម័យ និងបរិស្ថានជុំវិញកន្លែងធ្វើការ**

កំនត់ភារៈកិច្ចរបស់និយោជិកនិងនិយោជក ដែលទាក់ទងនិងការគ្រប់គ្រង និងដំណើរការនៃផ្នែកសុវត្ថិភាព អនាម័យ និងបរិស្ថានជុំវិញកន្លែងធ្វើការ ហើយអាចអោយ បុគ្គលឬនិតិបុគ្គលមករួមគ្នាដំណើរការជាមួយនិយោជកបាន

**និយោជក**

- បិទប្រកាសបំរាមគ្រោះថ្នាក់ តួនាទី បទបញ្ជា ទាក់ទងនិងសុវត្តិភាពអោយនិយោជិកបានដឹង
- រៀបចំការបណ្តុះនិងចាត់ត្រៀមឧបករណ៍ការពារសុវត្តិភាពសំរាប់និយោជក
- ចូលរួមជាមួយនិយោជកដ៏ទៃទៀតរួមគ្នាដំណើរការផ្នែកសុវត្តិភាព

**និយោជិក**

- រាយការណ៍ពេលយល់ថាគ្មានសុវត្តិភាព
- ចូលរួមជាមួយនិយោជក
- ពាក់ឧបករណ៍ការពារសុវត្តិភាពផ្ទាល់ខ្លួន

**ជំពូក 3 គណៈកម្មការខាងសុវត្តិភាព អនាម័យ និងបរិស្ថានជុំវិញកន្លែងធ្វើការ**

បង្កើតគណៈកម្មការខាងសុវត្តិភាព ដែលប្រកបដោយ ភាគីរដ្ឋ ភាគីនិយោជក ភាគីនិយោជិក និងអ្នកមានចំនេះដឹងខ្ពង់ខ្ពស់ ទាំងអស់ **30** នាក់មានតួនាទីដាក់សំណើរ ការយល់ឃើញរបស់ខ្លួនទៅរដ្ឋមន្ត្រី ទាក់ទងនិងនយោបាយ ផែនការ វិធីសាស្ត្រ ចេញច្បាប់ របស់ក្រសួងទាក់ទងនិងសុវត្តិភាព អនាម័យ និងបរិស្ថានជុំវិញកន្លែងធ្វើការរហូតដល់បាន ទទួលនិងវិនិច្ឆ័យពីការលើកឡើងរបស់និយោជក។

**ជំពូក 4 ការគ្រប់គ្រង ថែរក្សា**

កំនត់អោយនិយោជកត្រូវវាយតំលៃគ្រោះថ្នាក់ សិក្សាផលប៉ះពាល់ និងចាត់ធ្វើ ផែនការសុវត្តិភាព រហូតដល់បញ្ជាក់ពីការជួបប្រទះគ្រោះថ្នាក់ និងឧបទ្ទេវហេតុធ្ងន់ធ្ងរអោយ និយោជិកបានដឹងដូចតទៅៈ

កររណីនិយោជិកគ្រោះថ្នាក់ដល់ជីវិត ត្រូវរាយការណ៍ជាបន្ទាន់ ព្រមទាំងបញ្ជាក់ លំអិតពីមូលហេតុជាលាយលក្ខណ៍អក្សរក្នុងអំឡុងពេល 7 ថ្ងៃ

ករណីមានឧបទ្ទេវហេតុធ្ងន់ធ្ងរ រាយការណ៍ជាបន្ទាន់ ព្រមទាំងបញ្ជាក់លំអិត ពីមូលហេតុ ទំហំនៃការខូចខាត ការដោះស្រាយនិងការការពារជាលាយលក្ខណ៍អក្សរ ក្នុងអំឡុងពេល 7 ថ្ងៃ ករណីនិយោជិកមានគ្រោះថ្នាក់ ឬរងរបួសក្នុងពេលបំពេញ ការងារ ត្រូវបញ្ជូនឯកសារ(កថ. **16**)ក្នុងអំឡុងពេល ៧ ថ្ងៃ

**ជំពូក 5 បុគ្គលិកត្រួតពិនិត្យសុវត្ថិភាព**

កំនត់តួនាទីរបស់បុគ្គលិកត្រួតពិនិត្យសុវត្ថិភាព

- ចូលទៅក្នុង សប៉ក.ត្រួតពិនិត្យ ថតរូបនិងសម្លេងទាក់ទងនិង បរិស្ថានជុំវិញកន្លែងធ្វើការ ប្រើប្រាស់ឧបករណ៍វាស់និងត្រួតពិនិត្យគ្រឿងចក្រ ឧបករណ៍ក្នុងសប៉ក.រក្សាទុកគំរូវត្ថុធាតុដើមផលិតផលសំរាប់វិភាគ ទាក់ទងនិងសុវត្ថិភាព ហើយស៊ើបអង្កេត រកការពិត សំរុះសំរួល ហៅបុគ្គលដែលទាក់ទងមកបកស្រាយ ត្រួតពិនិត្យ ឬបញ្ជូន ឯកសារជា ភស្តុតាង(ម៉. 35)។

- បញ្ជាអោយអ្នកបំពានឬអ្នកមិនប្រតិបត្តិតាមព្រះរាជក្រិត្យនេះឬរកឃើញថាបរិស្ថានជុំវិញ កន្លែងធ្វើការ អាគារ ទីតាំង គ្រឿងចក្រ ឧបករណ៍ដែលនិយោជិក ប្រើបង្កអោយកើតគ្រោះថ្នាក់ដល់និយោជិក ដោយ បញ្ជាអោយឈប់ប្រព្រឹត្តល្មើស ហើយធ្វើ ការកែប្រែ ឬប្រតិបត្តិអោយបានសមរម្យនិងត្រឹមត្រូវក្នុងកំឡុងពេល 30 ថ្ងៃ (ម៉. 36)

- បញ្ជាអោយឈប់សកម្មភាពទាំងអស់រឺមួយផ្នែកជាបណ្តោះ អាសន្ន ដូចជាការប្រើប្រាស់ គ្រឿងចក្រ ឧបករណ៍ អាគារ ទីតាំង ដោយត្រូវបោះត្រា លើចំនុច ដែលអាចបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ និយោជិកនៅពេលដែលបានទទួលការអនុម័តពីអគ្គនាយកដ្ឋាន(ប្រធានអគ្គនាយកដ្ឋានជាអ្នកផ្តល់អោយ)(ម៉. 36 វ. 2)

- បញ្ជូនអោយបុគ្គលណាម្នាក់ចូលទៅធ្វើការកែតំរូវដើម្បីអោយត្រូវទៅតាមបទបញ្ញត្តិដែលបាន ដាក់ចេញនៅពេលដែលបានទទួលការអនុម័តពីអគ្គនាយកដ្ឋាន(ប្រធានអគ្គនាយកដ្ឋានជាអ្នកផ្តល់អោយ)

- និយោជកមានសិទ្ធិប្តឹងជំទាស់និងបទបញ្ជារបស់បុគ្គលិកត្រួតពិនិត្យ សុវត្ថិភាពក្នុងអំឡុងពេល 30 ថ្ងៃ

- ហាមនិយោជកបញ្ឈប់ការងាររបស់និយោជិកដោយសារតែ និយោជិក ប្តឹងផ្តល់ ព្រោះ និយោជិកជាសាក្សីដែលអាចផ្តល់ពត៍មានដល់បុគ្គលិក ត្រួតពិនិត្យសុវត្ថិភាព

**ជំពូក 6 មូលនិធិដើម្បីសុវត្ថិភាព អនាម័យ និងបរិយាកាសជុំវិញកន្លែងធ្វើការ**

ចាត់អោយមានខ្ទង់ចំនាយសំរាប់ចំនាយក្នុងការ ប្រកាសផ្សព្វផ្សាយ និងទំនុកបំរុង ជាប្រចាំ ហើយនិងសំរាប់អោយនិយោជកខ្ចីយកទៅកែតំរូវត្រង់ចំនុចដែល មិនទាន់មានសុវត្ថិភាព និងត្រូវចាត់អោយមានគណៈកម្មការគ្រប់គ្រងថវិការដើម្បីតម្លាភាព

ថវិការទាំងនោះបានមកពី

- ថវិការដែលរាជរដ្ឋាភិបាលទាំលាក់អោយ
- ថវិការប្រចាំឆ្នាំបានមកពីការទូទាត់សំណង
- ថវិការដែលបានមកពីការផាកពិន័យចំពោះនិយោជកដែលប្រព្រឹត្តិខុស
- ថវិការឬទ្រព្យសម្បត្តិដែលបានមកពីការបរិច្ចាគរបស់សប្បុរសជន
- ចំនូលពីការប្រើប្រាស់ថវិការនេះ
- ចំនូលពីសេវាកម្មផ្សេងៗដូចជាសំណើរសុំការអនុញ្ញាតនិងការចុះឈ្មោះជាសមាជិក
- ការប្រាក់ពីកម្ចីរបស់និយោជក

**ជំពូក 7 ស្ថាប័នលើកស្ទួយសុវត្ថិភាព អនាម័យ និងបរិយាកាសជុំវិញកន្លែងធ្វើការ**

កំនត់អោយមានស្ថាប័នលើកស្ទួយសុវត្ថិភាព អនាម័យ និងបរិយាកាស ជុំវិញកន្លែងធ្វើការក្នុងអំឡុងពេលមួយឆ្នាំដោយមានគោលបំណងដើម្បីលើកស្ទួយសុវត្ថិភាព។

**ជំពូក 8 ស្ថានទំងន់ទោស**

- សំរាប់និយោជកដែលល្មើសត្រូវជាប់គុក **1** ឆ្នាំ ឬ ពិន័យជាប្រាក់មិនលើសពី **400,000** បាត រឺ ត្រូវជាប់គុកហើយត្រូវពិន័យជាប្រាក់ទៀត។
- ក្នុងករណីមិនអនុវត្តន៍តាមបទបញ្ជារបស់បុគ្គលិកផ្នែកសុវត្ថិភាព តាមមាត្រា **36** វារៈ **2** ត្រូវជាប់គុកមិនលើសពី **2** ឆ្នាំ ឬត្រូវពិន័យជាប្រាក់ **800,000**បាត ឬត្រូវជាប់គុក ហើយត្រូវពិន័យជាប្រាក់ទៀត។

ស្ថានទំងន់ទោសស្រាលបំផុតត្រូវពិន័យជាប្រាក់មិនលើសពី **50,000** បាត ក្នុងករណីនិយោជកមិនបានប្រាប់ពីស្ថានភាពគ្រោះថ្នាក់ដល់និយោជិក ឬមិនបាន រាយការណ៍ប្រាប់បុគ្គលិកត្រួតពិនិត្យសុវត្ថិភាពពេលមានឧបទ្ទេវហេតុធ្ងន់ធ្ងរ។

## 4. ឱសានវាទ

គណៈកម្មការផ្នែកសុវត្ថិភាព អនាម័យ និងបរិយាកាសជុំវិញកន្លែងធ្វើការមានតួនាទី ត្រូវអនុវត្តន៍តាមព្រះរាជក្រិត្យនេះរហូតដល់មានការតែងតាំងគណៈកម្មការថ្មីពីសំណាក់ព្រះ រាជក្រិត្យ។ ក្រសួងត្រូវចេញច្បាប់ដោយអនុលោមតាមព្រះរាជក្រិត្យទាំង៨ជំពូក ក្នុងការគ្រប់គ្រងនិងការពារពលករ ដែលចេញក្នុងឆ្នាំព.ស.2541 មកធ្វើជាគោលក្នុងការអនុវត្តន៍។

## ផ្លាកសញ្ញាសំគាល់ដើម្បីសុវត្តិភាព

**1.** ផ្លាកសញ្ញាសំគាល់ដើម្បីសុវត្តិភាពនិងពណ៏ដែលគេនិយមប្រើចែកជា4ប្រភេទដើម្បី បញ្ជាក់ពីគោលបំណងនិងអត្ថន័យ

**2.** ត្រូវដាក់រូបសញ្ញាសំគាល់នៅត្រង់កណ្តាលរបស់ផ្លាកសញ្ញា ដោយមិនត្រូវអោយត្រួតលើ គំនូសកណ្តាល ចំពោះផ្លាកសញ្ញាហាមឃាត់

**3.** ក្នុងករណីដែលគ្មានរូបសញ្ញាសំគាល់សមស្របនិងអត្ថន័យដែលចង់បាន ត្រូវប្រើសញ្ញាសំគាល់ធម្មតា

ខាងក្រោមនេះជាផ្លាកសញ្ញាសំគាល់សុវត្តិភាពនីមួយៗ

និងផ្លាកសញ្ញាបន្ថែម

| ប្រភេទ | និមិត្សសញ្ញា | ព័ណដែលប្រើ | កំនត់សំគាល់ |
|---|---|---|---|
| សញ្ញាហាមឃាត់ |  | មានផ្ទៃពណ៏ស និងរុំព័ទ្ធជារង្វង់ ដោយពណ៏ក្រហម សញ្ញាសំគាល់ មានពណ៏ខ្មៅ | ផ្ទៃពណ៏ក្រហមត្រូវមានយ៉ាងតិច**35%** នៃផ្ទៃទាំងអស់របស់ផ្លាកសញ្ញា |
| សញ្ញាបម្រាម |  | មានផ្ទៃពណ៏លឿងនិងរុំព័ទ្ធជាត្រីកោណ ដោយពណ៏ខ្មៅ សញ្ញាសំគាល់មាន ពណ៏ខ្មៅ | ផ្ទៃពណ៏លឿងត្រូវមានយ៉ាងតិច**50%**នៃផ្ទៃទាំងអស់របស់ផ្លាកសញ្ញា |
| សញ្ញាបញ្ជា |  | មានផ្ទៃពណ៏ផ្ទៃមេឃ សញ្ញាសំគាល់មានពណ៏ស | ផ្ទៃពណ៏ផ្ទៃមេឃត្រូវមានយ៉ាងតិច**50%**នៃផ្ទៃទាំងអស់របស់ផ្លាកសញ្ញា |
| សញ្ញាប្រាប់ដំណឹងទាក់ទងនិងសុវត្តិភាព |  | មានផ្ទៃពណ៏បៃតង សញ្ញាសំគាល់មានពណ៏ស | - ផ្ទៃពណ៏បៃតងត្រូវមានយ៉ាង តិច**50%**នៃផ្ទៃទាំងអស់របស់ផ្លាកសញ្ញា<br>- អាចប្រើជារូបផ្ទាំងបួនជ្រុងក៏ បាន |

## ពណ៌សុវត្ថិភាពនិងពណ៌ផ្ទាត់

| ពណ៌សុវត្ថិភាព | អត្ថន័យ | ឧទាហរណ៍ក្នុងការប្រើប្រាស់ | ពណ៌ផ្ទាត់ |
| --- | --- | --- | --- |
|  | ប់ | - សញ្ញាអោយឈប់<br>- សញ្ញាអោយឧបករណ៍ ឈ ឈប់ជាបន្ទាន់ | ពណ៌ស |
|  | ប្រុងប្រយ័ត្ន | - បង្ហាញថាមានគ្រោះថ្នាក់ (ដូចជា ភ្លើងឆេះ ឧបករណ៍ ដែលអាចផ្ទុះ ធាតុវិទ្យុសកម្ម វត្ថុមានជាតិពុលជាដើម។) | ពណ៌ខ្មៅ |
|  | កំនត់អោយត្រូវតែអនុវត្តន៍ | - កំនត់អោយត្រូវតែពាក់ ឧបករណ៍ការពារសុវត្ថិភាពផ្ទាល់ខ្លួន<br>- ផ្លាកសញ្ញាបញ្ជា<br>- ផ្លាកសញ្ញាបម្រាម | ពណ៌ស |
|  | បង្ហាញស្ថានការណ៍សុវត្ថិភាព | - ផ្លូវគេចចេញ<br>-ច្រកចេញបន្ទាន់<br>- រ៉ូប៊ីនេទឹកសំរាប់ពន្លត់អគ្គីភ័យ<br>- ផ្នែកសង្គ្រោះបឋម<br>- ក្រុមសង្គ្រោះ<br>- សញ្ញាប្រាប់ដំណឹងទាក់ទងនិងសុវត្ថិភាព | ពណ៌ស |

កំនត់សំគាល់

**1.** ពណ៌ក្រហមទុកប្រើសំរាប់ឧបករណ៍ដែលទាក់ទងនិងអគ្គីភ័យ ឧបករណ៍សំរាប់ពន្លត់អគ្គីភ័យ និង កន្លែងសំរាប់ដាក់ឧបករណ៍ទាំងនោះ។

**2.** អាចប្រើពន្លឺពណ៌ក្រហមលាយទឹកក្រូចជំនួសពណ៌លឿងបាន តែមិនត្រូវប្រើជំនួសពណ៌លឿងដែលជាផ្លាកសញ្ញាសុវត្ថិភាព។ពន្លឺពណ៌ក្រហមលាយទឹកក្រូចអាចមើលឃើញបានច្បាស់ជាពិសេសចំពោះកន្លែងដែលងងិតខ្លាំង

# ផ្លាកសញ្ញាការពារសុវត្ថិភាព

## ផ្លាកសញ្ញាដាស់តឿន












ផ្លាកសញ្ញាការការពារសុវត្ថិភាព
ផ្លាកសញ្ញាបង្គាប់បញ្ជា
ពាក់ឧបករណ៍
ពាក់ស្រោមដៃ

# ផ្លាកសញ្ញាការការពារសុវត្ថិភាព

## ផ្លាកសញ្ញាសុវត្ថិភាព



## ផ្លាកសញ្ញាការការពារសុវត្ថិភាព

### ផ្លាកសញ្ញាបំរាម

















## ផ្លាកសញ្ញាទាក់ទងជាមួយការការពារអគ្គិភ័យ









3
ស. សវតិភាព
ស.សាងសំនឹកអន្តរាយ
ស.សម្រួតគ្រោះថ្នាក់
ស.សម្រួលកែខៃឲ្យមានសុវត្ថិភាព


5
វិធីប្រើឧបករណ៍យ៉ាងមានសុវត្ថិភាព
1
ឧបករណ៍ត្រូវមានសភាពល្អជានិច្ច
2
ប្រើឧបករណ៍ឲ្យត្រូវនិងការងារ
3
ត្រូវសម្អាតនិងត្រួតពិនិត្យគ្រប់ពេលក្រោយរួចពីការងារ
4
ពាក់ឧបករណ៍ការពារគ្រោះថ្នាក់ផ្ទាល់ខ្លួន
5
កន្លែងដាក់ដៃត្រូវទូលាយជៀសវៀងគ្រោះថ្នាក់

# ផ្នែកពលករសម្ព័ន្ធភាព

## (ด้านแรงงานสัมพันธ์)

## ពលករសម្ព័ន្ធភាព

ពលករសម្ព័ន្ធភាព មានន័យថា ការសម្ព័ន្ធភាពរវាងបុគ្គលិកនៅក្នុងអង្គភាពឬការទំនាក់ ទំនងរវាងថៅកែជាមួយកូនឈ្នួលនៅក្នុងការជួលធ្វើការរហូតដល់លាលែងចេញពីការងារ

ជាបែបវិធីការគ្រប់គ្រងដែលធ្វើអោយមានការពេញចិត្តដល់សេចក្តីត្រូវការរបស់កូនឈ្នួលនៅក្នុងការកំនត់យុទ្ធសាស្ត្រការងារ រហូតដល់មធ្យោបាយក្នុងការអនុវត្តន៍ការងារបន្ថែម ទំនាក់ទំនងរវាងថៅកែជាមួយកូនឈ្នួល ការទំនាក់ទំនងរវាងអ្នកធ្វើការជាមួយគ្នានិងការ ទំនាក់ទំនងរវាងផ្នែកគ្រប់គ្រងជាមួយអ្នកធ្វើការគ្រប់រូប ក្រៅពីនេះ ការទំនាក់ទំនងពលករ នៅមានន័យថាសេវាកម្មនិងផលប្រយោជន៍ដែលផ្នែកគ្រប់គ្រងរៀបចំអោយបុគ្គលិក មានដូចជាសុខមាលភាពផ្សេងៗ ប្រាក់ឧបត្ថម្ភ ថ្លៃឈប់សំរាកប្រពៃណីជាតិ ថ្ងៃឈប់សំរាក ឈឺជាដើម។

## សម្ព័ន្ធភាពរវាងនិយោជកជាមួយនិយោជិក

### លក្ខណៈសម្ព័ន្ធភាព

និយោជកជាមួយនិយោជកមានទំនាក់ទំនងនៅក្នុងលក្ខណៈសំខាន់ **2** ប្រការគឺៈ

**1.**ការទំនាក់ទំនងផ្នែកការគ្រប់គ្រងដូចជា ការប្រើអំណាចបង្គាប់បញ្ជារ កំណត់ នយោបាយ របៀបច្បាប់ទំលាប់ការរក្សាវិន័យ ការវិនិច្ឆ័យ ការបញ្ជារដោយនិយោជក និងផ្នែកគ្រប់គ្រង រួមទាំងការបើក ឱកាសអោយនិយោជិកមានការចូលរួមនៅក្នុងការ គ្រប់គ្រងនិងសំរេចចិត្តនៅក្នុងរូបបែបផ្សេងៗ ដូចជាការប្រើប្រព័ន្ធចូលរួមពិភាក្សាឬប្រព័ន្ធការប្តឹង ប្រព័ន្ធការស្នើរយោបល់

**2.**ការទំនាក់ទំនងផ្នែកសេដ្ឋកិច្ច ដូចជា ការផ្តល់ផលប្រយោជន៍ផ្សេងជំនួសគ្នាទៅវិញ ទៅមកគឺករណីឈ្នួលអនុវត្តន៍ការងារយ៉ាងមានប្រសិទ្ធភាពដើម្បីបង្កើតផលការផលិតនិងផលកំរៃអោយដល់ថៅកែ

## តួនាទីផ្នែកពលករសម្ព័ន្ធភាព

### តួនាទីរបស់និយោជក

**1.**តួនាទីនៅក្នុងការគ្រប់គ្រងប្រព័ន្ធផ្ទៃក្នុងគ្រឹះស្ថានប្រកបអាជីវកម្ម

- មានប្រព័ន្ធការគ្រប់គ្រងការងារបុគ្គលិកដែលទាន់សម័យនិងមានប្រសិទ្ធិភាព
- កំនត់នយោបាយការជួលអោយបានច្បាស់លាស់ ងាយយល់
- កែសំរួលប្រព័ន្ធការបែងចែកតំណែងអោយទាន់សម័យជានិច្ចជាកាល
- កែសំរួលទីកន្លែងធ្វើការ សភាពការធ្វើការងារ និងសុវត្ថិភាពនៅក្នុងការធ្វើការ

- រៀបចំរចនាសម្ព័ន្ធ រៀបចំអង្គការបណ្តាញបញ្ជាការអោយមានរបៀបបែបផែន
- រៀបចំប្រព័ន្ធនាំសារនិងការប្តឹងដែលមានប្រសិទ្ធិភាព
- មានដំណាក់កាលក្នុងផ្នែកវិន័យនិងការដាក់ទោសដោយយុត្តិធម៌

**2.** តួនាទីនៅក្នុងផ្នែកការពារបញ្ហា

**2.1** នៅក្នុងរយៈខ្លី

- គ្រប់គ្រងនិយោជិកអោយបានទទួលសិទ្ធិប្រយោជន៍តាមច្បាប់ការងារ និងតាមរបៀប ច្បាប់ទំលាប់របស់អង្គភាព
- គោរពសិទ្ធិរបស់និយោជិកជួយពិភាក្សាដោយមានហេតុផល
- ផ្តល់ការយល់ព្រមសហគមន៍ពលករនិងប្រើប្រព័ន្ធការពិភាក្សាជាមួយ សហគមន៍ពលករ
- សិក្សាជំនួយបន្ថែមលើការអនុវត្តន៍យ៉ាងទូលំទូលាយទាន់ស្ថានការណ៍ ដោយផ្អែកលើគ្រឹះពិតប្រាកដ យុត្តិធ៌ម និង សុច្ចរិត

**2.2** នៅក្នុងរយៈវែង

- ទំនុកបំរុងអោយនយោជិកមានការចូលរួមនៅក្នុងការបញ្ចេញមតិដើម្បីកែ សំរួលការងារនិងភ្នាក់ងារអោយល្អឡើង រួមទាំងមានការចូលរួមសំណូមពរដើម្បីកែសំរួល សភាពការធ្វើការងារ
- ទំនុកបំរុងអោយនិយោជិកបានទទួលការបណ្តុះបណ្តាលផ្នែកទំនាក់ទំនង ពលករនិងការអភិវឌ្ឍន៍ ជំនាញនៅក្នុងការអនុវត្តន៍ការងារនៅពេលមានប្រព័ន្ធការផលិត ការប្រើប្រាស់គ្រឿងចក្រថ្មីៗ
- រៀបចំផែនការកំលាំងមនុស្សអោយសមស្របជាមួយស្ថានភាពសេដ្ឋកិច្ច
- រួបរួមទិន្នន័យស្វែងរកមូលហេតុរបស់បញ្ហាដែលកើតឡើងដើម្បីរៀបចំ វិធីការពារ

3. តួនាទីនៅក្នុងការដោះស្រាយបញ្ហាករណីមានទំនាស់

- កំណត់វិធីនៅក្នុងការដោះស្រាយបញ្ហាទំនាស់ដោយមានការពិភាក្សារួម

- ដោះស្រាយបញ្ហាដោយផ្អែកលើច្បាប់និងបទបញ្ជារនិងហេតុផល

- ប្រើប្រាស់វិធីសាស្រ្តសំរេចចិត្តដែលមានការប្រុងប្រយ័ត្ននិងចិត្តសុច្ចរិត

**តួនាទីរបស់និយោជិក**

ការទំនាក់ទំនងដែលល្អនៅក្នុងទីតាំងប្រកបកិច្ចការងារនឹងកើតឡើងបាននោះ មិនមានន័យថាចំពោះនិយោជកតែម្យ៉ាងដែលនឹងក្លាយជាអ្នកបង្កើត ប៉ុន្តែនឹងត្រូវរួមគ្នា ទាំងពីរផ្នែក នាំអោយនិយោជិកគួរមានការអនុវត្តន៍ដូចខាងក្រោម:

- គោរពសិទ្ធិរបស់និយោជក ដូចជា ការដាក់បញ្ជារការងារ ការត្រួតពិនិត្យការងារ និងការប្រែប្រួលតួនាទីដោយស្មើរភាព

- អនុវត្តន៍តាមច្បាប់ទំលាប់ដោយត្រឹមត្រូវ តាមរបៀបផ្សេងៗជាលក្ខណៈ មូលដ្ឋានដែលនិងធ្វើអោយមនុស្សច្រើនក្រុមនៅជាមួយគ្នាដោយមានរបៀប

- តាំងចិត្តអនុវត្តភារកិច្ចតាមដែលបានទទួល

- មានការសំរេចបានផ្នែកពលករសមល្មម មិនថាជារបៀបឬច្បាប់ទំលាប់ពលករក៏ដោយ ដើម្បីនឹងបានទទួលសិទ្ធិភារកិច្ចនិងការ អនុវត្តខ្លួនអោយសមរម្យ

- មានសេចក្តីសំខាន់សមរម្យនៅក្នុងការដែលនឹងស្នើរយោបល់ ឬប្តឹងនៅក្នុងរឿងផ្សេងៗ

- ការដែលនឹងសុំបន្ថែមសភាពការជួលនឹងត្រូវពិចារណារឿងផ្សេងៗ អោយសំរេច ទោះបីជារហូតដល់និយោជកអាចនឹងអោយបានឬមិនបាន

- កុំល្មើសច្បាប់របស់ប្រទេសដូចជា ករណីប្រើប្រាស់សិទ្ធិប៉ះពាល់ដល់ច្បាប់ ពលករ ប៉ុន្តែនៅ ខណ:ដែលបញ្ឈប់ការងារអាច នឹងមានការទង្វើរផ្ទុយពីច្បាប់ផ្សេង ធ្វើអោយ លំបាក

- នៅក្នុងការនឹងស្វែងរកផ្លូវច្បាប់ដែលផ្ទុយពីច្បាប់ពលករការទំនុកបំរុងពលករសម្ព័ន្ធ ភាពដែលល្អនៅក្នុងគ្រឹះស្ថានប្រកបអាជីវកម្ម

**ដំណើរការការទំនុកបំរុងពលករសម្ព័ភាពដ៏ល្អ**

- និយោជកនិងនិយោជិក ថ្លឹងថ្លែងដល់ផលប្រយោជន៍រួមគ្នា
- ទាំងពីរភាគីមានចំណេះដឹងក្នុងការផ្តល់អោយនិងការទទួលយក
- មានប្រព័ន្ធការនាំសារដែលមានប្រសិទ្ធិភាព
- មានប្រព័ន្ធរដ្ឋបាលនិងបញ្ចប់ការប្តឹងប្តល់ដោយស្មើរភាព
- មានការរួមប្រឹក្សាជារឿយៗ
- បង្កើតសេចក្តីជិតស្និត ការមានជឿជាក់គ្នាទៅវិញទៅមក
- ព្រមទទួលហេតុផលគ្នាទៅវិញទៅមក
- បើកឱកាសអោយនិយោជិកមានការចូលរួមនៅក្នុងការគ្រប់គ្រងច្រើនឡើង
- គោរពសិទ្ធិនិងភារកិច្ចរបស់ភាគីផ្សេងទៀត

## តួនាទីនៅក្នុងការទំនុកបំរុងពលករសម្ព័ន្ធភាពជានិច្ចជាកាលៈ

### តួនាទីនិយោជកនិងផ្នែកគ្រប់គ្រង

- មាននយោបាយផ្នែកពលករសម្ព័ន្ធភាពដែលច្បាស់លាស់និងបើកបង្ហាញ ដោយចំពោះការប្រើប្រាស់ប្រព័ន្ធការប្រឹក្សានិងការបង្កើតការរួមគ្នារវាងនិយោជិក និយោជក

- ផ្នែកគ្រប់គ្រងគួរចាប់ផ្តើមកំនត់ទិសដៅដែលនឹងរួមគ្នាជាមួយនិយោជិក

- ផ្នែកគ្រប់គ្រងគួរតែរៀបចំគំរោងផែនការដើម្បីប្រើវិនិយោគនៅផ្នែកការអភិវឌ្ឍន៍ ទំនាក់ទំនងពលករ

- ផ្នែកគ្រប់គ្រងនិងប្រធានគ្រប់ថ្នាក់នឹងត្រូវបានទទួលការផ្ទេរនយោបាយ ក្របខ័ណ្ឌនិងទិសដៅការធ្វើការងារខាងផ្នែកទំនាក់ទំនងពលកររបស់ក្រុមហ៊ុន

- បណ្តុះបណ្តាលជំនាញដល់ផ្នែកគ្រប់គ្រងនិងប្រធានដ៏ល្អអោយទៅប្រធាន ការងារគ្រប់ជាន់ថ្នាក់

- បណ្តុះបណ្តាលផ្នែកគ្រប់គ្រងនិងប្រធានការងារគ្រប់ជាន់ថ្នាក់នៅក្នុងរឿង ទំនាក់ទំនងពលករ ការប្រឹក្សានិងការចូលរួមក្នុងធ្វើការងារ

- យល់ព្រមនិងផ្តល់ភាពស្មោះត្រង់ដល់និយោជិកគ្រប់លំដាប់ថ្នាក់

- ផ្តល់ឱកាសអោយនិយោជិកមានការចូលរួមបញ្ចេញគំនិតនិងការសំរេចចិត្ត នៅក្នុងអ្វីដែលទាក់ទងជាមួយនិយោជិកដោយត្រង់

- បង្កើតលក្ខខ័ណ្ឌដែលនឹងអោយនិយោជិកមានឱកាសប្រើជំនាញនិង សក្តានុពលភាពរបស់ពួកគាត់យ៉ាងពេញលេញនៅក្នុងការអភិវឌ្ឍន៍គ្រឹះស្ថានប្រកបអាជីវកម្ម

- បង្កើតការជឿជាក់គ្នាដោយការបង្ហាញភាពស្មោះត្រង់របស់ផ្នែកគ្រប់គ្រង ដែលមានដល់និយោជិក

- ផ្នែកគ្រប់គ្រងគួរនឹងបង្ហាញអោយឃើញដល់សេចក្តីព្យាយាមដែលនឹងកែ សំរួលគុណភាពជីវិតរបស់និយោជិក

- ផ្នែកគ្រប់គ្រងគួរអោយព័ត៏មានសំខាន់របស់ក្រុមហ៊ុនដែលត្រឹមត្រូវនិង ទាន់ហេតុការណ៍ដល់សភាពពលករឬអ្នកជំនួសរបស់និយោជិក

**តួនាទីរបស់និយោជិក**

- និយោជិកត្រូវយល់ដឹងថានិយោជិកជាមួយនិយោជកផលប្រយោជន៍រួមគ្នា ដូចនេះនឹងមិនត្រូវគិតដល់តែផលប្រយោជន៍របស់និយោជិកតែម្យ៉ាង ប៉ុន្តែនឹងត្រូវគិតដល់ ផលប្រយោជន៍របស់របស់អង្គភាពជំនួញផងដូចនេះការស្នើសុំរបស់និយោជិកគួរមាន ហេតុផលនិងមានភាពដែលអាចទៅបាន

- គួរទំនុងបំរុងរបៀបវិន័យការធ្វើការនិងចរិយធម៏នៅក្នុងការងារធ្វើការងារយ៉ាង ពិតប្រាកដ

- និយោជិកយល់ព្រមទទួលប្រព័ន្ធប្រឹក្សានិងឃ្លាំមើលគ្នាដើម្បីជួយជំរុញអោយ អង្គភាពជំនួញរីកចំរើន

- គួរមានចំណេះដឹងទាក់ទងជាមួយស្ថានការណ៍សេដ្ឋកិច្ចនៅក្នុងភាពរួម និងស្ថានការណ៍ផ្នែកជំនួញរបស់គ្រឹះស្ថានប្រកបអាជីវកម្ម

**ចំនុចគួរប្រតិបត្តិដើម្បីការទំនុកបំរុងពលករសម្ព័ន្ធភាពយ៉ាងល្អ:**

- មានការស្មោះត្រង់ចំពោះគ្នា

- ជឿជាក់គ្នាទៅវិញទៅមក

- ផ្តល់ការយល់ព្រម

- ទទួលខុសត្រូវចំពោះភារកិច្ច

- ពិភាក្សារួមគ្នា
- ដោះស្រាយបញ្ហាដោយរហ័ស
- ប្រើមូលដ្ឋានបត់បែន
- ផ្លាស់ប្តូរទិន្នន័យ
- ផលតបស្នងយ៉ាងសមរម្យ
- អនុវត្តដោយស្មើរភាព
- រក្សារបៀបវិន័យ
- យុត្តិធម៌ចំពោះគ្នា
- ផ្តល់អោយមានការចូលរួមចំណែក
- ផ្តល់ភាពសំខាន់អោយដល់ប្រព័ន្ធប្តឹង
- ផ្តល់ឱកាស
- យកគ្រឹះគ្រួសារជាមូលដ្ឋាន
- បង្កើតសីលធម៌និងកំលាំងចិត្ត
- ផ្សព្វផ្សាយព័ត៌មានអោយបានច្បាស់លាស់

- ផ្តល់ចំណេះដឹងខាងការបណ្តុះបណ្តាលជានិច្ចជាកាល
- មានមនុស្សសម្ព័ន្ធភាព

**ចំនុចគួរលើកលែងដើម្បីទំនុកបំរុងពលករសម្ព័ន្ធភាពដ៏ល្អ:**

- មានអគតិចំពោះគ្នា
- មិនទុកចិត្តគ្នា
- បែងបក្សពួក
- ព្រងើយកន្តើយចំពោះភារកិច្ចការងារ
- ប្រើច្បាប់ត្រឹមតែម្យ៉ាង
- មើលរំលងបញ្ហាតូចៗ
- ចចេស
- គ្រប់គ្រងអំណាចការគិតតែម្នាក់ឯង
- យកចំណូលតែម្យ៉ាង
- ជ្រើសរើសអនុវត្តន៍
- ផ្លាស់ប្តូរភ្លាមៗ
- ទុច្ចរិតចំពោះគ្នា
- សំរេចចិត្តតែផ្នែកម្ខាង
- ព្រងើយកន្តើយចំពោះការស្នើរសុំ

- ព្រងើយកន្តើយចំពោះការអោយយោបល់
- អោយបុគ្គលខាងក្រោមកទាក់ទង
- ដាក់ការងារតែម្យ៉ាង
- និយាយអោយមានរឿង
- ខ្វះការអភិវឌ្ឍន៍
- បង្កើតសំពាធអោយផ្នែកដទៃទៀត

## ប្រយោជន៍របស់ពលករសម្ព័ន្ធភាពដ៏ល្អ:

**និយោជក**

- ដំណើរការការងារបានបន្តបន្ទាប់ មានប្រសិទ្ធភាព មានផលចំណេញ ការងារីកចំរើន
- មិនខាតពេលវេលា មិនខូចអារម្មណ៍ និងមិនខូចមុខ
- អាចរក្សារបៀបវិន័យយ៉ាងស្ងប់សុខនៅក្នុងគ្រឹះស្ថាន
- ការចំណាយយ៉ាងសមរម្យ

**និយោជិក**

- មានសីលធម៌នៅក្នុងការធ្វើការ
- បានទទួលថ្លៃឈ្នួល មានសុខមាលភាព ផលប្រយោជន៍ សភាពការងារល្អ និងការធ្វើការបានល្អឡើង
- មានឱកាសបង្ហាញភាពមិនលំនាំគេ អាចអភិវឌ្ឍន៍ភាពរីកចំរើននៅក្នុង អាជីពការងារ
- មានភាពគង់វង្សនៅក្នុងការងារ

**ប្រជាជនទូទៅ**

- នៅក្នុងឋានៈអ្នកបរិភោគបានទទួលទំនិញនិងសេវាកម្មដ៏ល្អ

**ប្រទេសជាតិ**

- គាំទ្របរិយាកាសនៅក្នុងការវិនិយោគទុន
- ការពង្រីកខ្លួនរបស់ឧស្សាហកម្ម ការរីកចំរើនខាងសេដ្ឋកិច្ច
- ភាពស្ងប់សុខក្នុងសង្គម

# ផ្នែកសុខមាលភាពពលករ

## (ด้านสวัสดิการแรงงาน)

## សុខមាលភាពការងារ

ការផ្តល់សុខមាលភាពការងារដល់ពលករជាបច្ច័យសំខាន់ដែលអាចជួយលើកស្ទួយគុណភាពជីវិតពលករនិងគ្រួសារពលករ។ ការយកចិត្តទុកដាក់របស់ថៅកែដោយការផ្តល់នូវសុខមាលភាពការងារដល់ពលករ តែងតែធ្វើឲ្យពលករគោរពស្រឡាញ់ថៅកែវិញ ។ ដូចនេះវាបានជំរុញឲ្យពលករមានទឹកចិត្តប្រឹងប្រែងធ្វើការ ធ្វើឲ្យលទ្ធផលការងារទទួលបានបរិមាណនិងគុណភាពខ្ពស់ ។ ស្របជាមួយគ្នានេះដែរ ការផ្តល់សុខមាលភាពការងារដល់ពលករ ថែមទាំងជួយរឹតចំណងសាមគ្គីភាពរវាងថៅកែនិងពលករ និងអាចជួយកាត់បន្ថយការប្រឈមមុខដាក់គ្នារវាងភាគីទាំងពីរផងដែរ ។ ជាលទ្ធផលវាធ្វើឲ្យកិច្ចដំណើរការរបស់សហគ្រាសប្រព្រឹត្តិទៅយ៉ាងរលូន។

អគ្គនាយកដ្ឋានសុខមាលភាពនិងការគ្រប់គ្រងពលករបានអនុវត្តន៍គោលការណ៍សុខមាលភាពពលករដោយបានជួយជ្រោមជ្រែងឲ្យមានការផ្តល់សុខមាលភាពការងារដល់ពលករនៅគ្រប់បណ្តាសហគ្រាសទាំងអស់។ ដោយមានជំនឿថាការដែលធ្វើឲ្យពលករមានសុខមាលភាពល្អប្រសើរនោះ វាមិនត្រឹមតែធ្វើឲ្យពលករមានកំលាំងចិត្តធ្វើការប៉ុណ្ណោះទេ តែវាបានជួយឲ្យពលករកាត់បន្ថយការសុំច្បាប់ការងារនិងប្តូរការងារថែមទៀត។ សរុបមកវាបាននាំមកនូវប្រសិទ្ធិភាពការងារល្អនិងបង្កើនការផលិត។

ក្នុងកិច្ចដំណើរការផ្តល់សុខមាលភាពការងារដល់ពលករនៅតាមសហគ្រាសនានា អគ្គនាយកដ្ឋានសុខមាលភាពនិងការគ្រប់គ្រងពលករបានអនុវត្ត 3 ភារកិច្ចសំខាន់ៗ ដូចមានចែងនៅក្នុងច្បាប់ក្រសួងការងារ ព.ស 2545 ទាក់ទងនឹងសុខមាលភាពនិងការគ្រប់គ្រងពលករ។

1. កំណត់និងអភិវឌ្ឍន៏គំរូនៃការផ្តល់សុខមាលភាពការងារ។
2. លើកស្ទួយ ឧបត្ថម្ភគាំទ្រ និងជំរុញឲ្យមានការផ្តល់សុខមាលភាព។
3. សហការណ៏ឬឧបត្ថម្ភគាំទ្រ ក្នុងការអនុវត្តន៏ការងាររបស់អង្គភាពដែលទាក់ទង។

ក្នុងការអនុវត្តន៏ខាងលើ សុខមាលភាពការងារត្រូវបានបែងចែកជា 2 ប្រភេទគឺ:

1. សុខមាលភាពការងារតាមច្បាប់កំណត់។
2. សុខមាលភាពការងារក្រៅពីច្បាប់កំណត់។

### សុខមាលភាពការងារតាមច្បាប់កំណត់

សុខមាលភាពការងារតាមច្បាប់កំណត់ជាសុខមាលភាពដែលទទួលបានការពិចារណាថាជាតម្រូវការចំបាច់របស់ពលករនៅតាមសហគ្រាស។ អាស្រ័យហេតុនេះ ព្រះរាជក្រឹតគ្រប់គ្រងពលករព.ស 2541 បានកំណត់គោលការណ៏សុខមាលភាពការងារចំនួន៣ប្រការ ដូចខាងក្រោមនេះ

ប្រការ១ផ្តល់អំណាចដល់រដ្ឋមន្ត្រីក្នុងការតាក់តែងច្បាប់ដែលកំណត់ឱ្យថៅកែផ្តល់សុខមាលភាពផ្សេងៗដល់ពលករ។ រដ្ឋមន្ត្រីតាក់តែងច្បាប់ដើម្បីអនុវត្តជាធរមាន ដោយឱ្យសហគ្រាសដែលមានពលករចាប់ពី 1 នាក់ឡើងទៅផ្តល់សុខមាលភាពការងារដល់ពលករ ពោលគឺច្បាប់ក្រសួងការងារទាក់ទងនឹងសុខមាលភាពក្នុងសហគ្រាសព.ស 2548 ត្រូវចូលជាធរមានចាប់តាំងពីថ្ងៃទី 25 ខែកញ្ញា ព.ស 2548 តទៅ។ ច្បាប់នេះមានខ្លឹមសារដូចតទៅនេះ

ចំនុច **1** នៅក្នុងកន្លែងធ្វើការងាររបស់និយោជិក អោយនិយោជករៀបចំអោយមាន

(**1**)ទឹកស្អាតសំរាប់ទទួលទានមិនតិចជាងមួយកន្លែងសំរាប់និយោជិក មិនលើសពី 40 នាក់និងបន្ថែមឡើងនៅក្នុងអត្រាមួយកន្លែងសំរាប់និយោជិកគ្រប់ៗ40នាក់ សំណល់របស់៤០នាក់ប្រសិនបើលើស 20 នាក់ ត្រូវចាត់ទុក ជា **40** នាក់

(**2**)បន្ទប់ទឹកនិងបង្គន់តាមបែបនិងចំនួនដែលកំនត់នៅក្នុងច្បាប់ថាដោយការ ត្រួតពិនិត្យអគារនិងច្បាប់ផ្សេងដែលទាក់ទងនិងមានការថែរក្សាភាពស្អាត អោយនៅ ក្នុងសភាពដែលត្រូវតាមសុខលក្ខណៈជាប្រចាំរាល់ថ្ងៃ អោយនិយោជករៀបចំអោយ មានបន្ទប់ទឹកនិងបង្គន់ញែកចេញពីគ្នាសំរាប់និយោជិកប្រុសនិងនិយោជិកស្រី និងនៅក្នុងករណីដែលមាននិយោជិកជាជនពិការ អោយនិយោជករៀបចំអោយមានបន្ទប់ទឹក និងបង្គន់សំរាប់មនុស្សពិការញែកចេញជាពិសេស

ចំណុច **2** នៅក្នុងកន្លែងធ្វើការរបស់និយោជិក អោយនិយោជករៀបចំអោយមាន វត្ថុចាំបាច់នៅក្នុងការសង្គ្រោះបឋមនិងការព្យាបាល ដូចតទៅនេះ

(**1**)ទីកន្លែងធ្វើការដែលមាននិយោជិកធ្វើការតាំងតែ **10** នាក់ឡើងទៅ ត្រូវរៀបចំអោយមានឧបករណ៍ពេទ្យនិងថ្នាំដើម្បីប្រើប្រាស់នៅក្នុងសង្គ្រោះបន្ទាន់នៅក្នុងចំនួនដែលគ្រប់គ្រាន់ យ៉ាងហោចតាមបញ្ជីរដូចខាងក្រោមនេះ

(**1.1**)កន្ត្រៃ

(**1.2**)កែវថ្នាំទឹក និងកែវថ្នាំគ្រាប់

(**1.3**)ម្ជុលខ្ទាស់

(**1.4**)ចានទឹក

(**1.5**)ប្រដាប់លាបថ្នាំ

**(1.6)**បំពង់ស្ទង់កំដៅ

**(1.7)**ដង្កាប់មាត់ក្រពើ

**(1.8)**ស្កុត

**(1.9)**ក្រណាត់បីជ្រុង

**(1.10)**ខ្សែរចងរិតឃាត់ឈាម

**(1.11)**សំឡី ក្រណាត់រុំជើង ក្រណាត់រុំដំបៅ និងបង់បិតដំបៅ

**(1.12)**ទុយោបន្តក់ថ្នាំ

**(1.13)**ក្រមួនលាបបំបាត់ហើម

**(1.14)**ថ្នាំក្រហមលាបដំបៅ

**(1.15)**ថ្នាំលាងដំបៅ

**(1.16)**ទឹកអំបិលស៊េ

**(1.17)**ថ្នាំលាបកន្ទួលដែលមិនបណ្តាលមកការឆ្លងមេរោគ

**(1.18)**ថ្នាំចាញ់អាកាសធាតុ

**(1.19)**ថ្នាំលាបកន្ទួលរមាស់

**(1.20)**ថ្នាំព្យាបាលហើមពោះ

**(1.21)**ថ្នាំបន្ថយកំដៅ

**(1.22)**ថ្នាំព្យាបាលការរលាកទឹកក្តៅ

**(1.23)**ថ្នាំបន្ថយជាតិអាស៊ីតក្នុងក្រពះ

(**1.24**)ស្រោមអាម៉ូញាក់ក្រអូប

(**1.25**)អាកុលជូតដំបៅ

(**1.26**)ក្រមួនលាបភ្នែក

(**1.27**)ពែងលាងភ្នែក

(**1.28**)ទឹកថ្នាំបរិចលាងភ្នែក

(**1.29**)ថ្នាំបន្តក់ភ្នែក

(**2**) ទីកន្លែងធ្វើការដែលមាននិយោជិកនៅខណៈជាមួយគ្នាតាំងតែ 200 នាក់ ឡើងនាក់ ត្រូវរៀបចំអោយមាន

(**2.1**) ឧបករណ៍ពេទ្យនិងថ្នាំដើម្បីប្រើប្រាស់នៅក្នុងការសង្គ្រោះបន្ទាន់ តាម(**1**)

(**2.2**) បន្ទប់ព្យាបាលព្រមទាំងគ្រែអ្នកជំងឺ

សំរាកយ៉ាងតិចមួយគ្រែ ឧបករណ៍ពេទ្យនិងថ្នាំ ក្រៅពីទីបញ្ជាក់ទុកនៅ (**1**) តាមភាពចាំ បាច់ និងគ្រប់គ្រាន់ ដល់ការព្យា បាលដំបូង

(**2.3**) មន្ទីរពេទ្យតាំងតែលំដាប់មន្ទីរពេទ្យបច្ចេកទេសឡើងទៅទុក ជានិច្ចយ៉ាងតិចម្នាក់គ្រប់ពេលវេលាធ្វើការ

(**2.4**) ពេទ្យផ្នែកបច្ចុប្បន្នជាន់ទីមួយយ៉ាងតិចម្នាក់ ដើម្បីពិនិត្យ ព្យាបាល មិនតិចជាងមួយសប្តាហ៍ចំនួនពីរដងនិងពេលរួមវេលាហើយត្រូវមិនតិចជាងមួយសប្តាស៍ប្រាំមួយម៉ោងនៅក្នុងពេលធ្វើការងារ

(**3**) ទីកន្លែងធ្វើការដែលមាននិយោជិកធ្វើការនៅខណៈជាមួយគ្នាតាំងតែមួយ ពាន់នាក់ឡើងទៅត្រូវរៀបចំអោយមាន

(**3.1**) ឧបករណ៍ពេទ្យនិងថ្នាំដើម្បីប្រើនៅក្នុងការសង្គ្រោះបន្ទាន់តាម (1)

(**3.2**) បន្ទប់ព្យាបាលព្រមទាំងគ្រែសំរាកអ្នកជំងឺយ៉ាងតិចពីរគ្រែ ឧបករណ៍ពេទ្យនិងថ្នាំក្រៅពីបញ្ជាក់ទុកនៅ (**1**) តាមភាពចាំបាច់និងគ្រប់គ្រាន់ ដល់ការព្យាបាលដំបូង

(**3.3**) មន្ទីរពេទ្យតាំងតែលំដាប់ព្យាបាលបច្ចេកទេសឡើងទៅទុក ជានិច្ចយ៉ាងតិចពីរនាក់គ្រប់ពេលវេលាធ្វើការ

(3.4) ពេទ្យបច្ចុប្បន្នមួយជាន់យ៉ាងតិចណាស់មួយនាក់ដើម្បីពិនិត្យ ព្យាបាលមិនតិចជាងមួយសប្តាហ៍បីដង និងនៅពេលរួមពេលវេលាត្រូវមិនតិចជាងមួយ សប្តាហ៍ដប់ពីរម៉ោងនៅក្នុងពេលធ្វើការងារ

(3.5) យានជំនិះត្រូវត្រៀមព្រមនឹងបញ្ជូននិយោជិកទៅមន្ទីរពេទ្យដើម្បី អោយទទួលការព្យាបាលបានភ្លាម

ចំណុច 3 និយោជកអាចធ្វើការយល់ព្រម ដើម្បី បញ្ជូន និយោជិកចូលមកទទួលការព្យាបាលនៅមន្ទីរពេទ្យដែលបើកបំរើសេវាកម្មរហូតម្ភៃបួនម៉ោង និងជាមន្ទីរដែលនិយោជកអាចនាំនិយោជិកបញ្ជូន ទៅទទួលការព្យាបាលបានដោយភាព ងាយស្រួលនិងឆាប់រហ័ស ជំនួសការរៀបចំអោយមានពេទ្យតាមចំណុចទី(2) ឬ ចំណុចទី(3)បានដោយត្រូវទទួលការអនុញ្ញាតពីអធិបតី ឬអ្នកដែលអធិបតីប្រគល់អោយ

ការអោយនិយោជករៀបចំសុខមាលភាពតាមច្បាប់ក្រសួងបានកំណត់ទុកជាភារកិច្ចរបស់នាយកដ្ឋានត្រូវមានការតាមដានដោយបុគ្គលិករបស់នាយកដ្ឋានសុខមាលភាពនិងគ្រប់គ្រងពលករ និងនាយកដ្ឋានសុខមាលភាពនិងគ្រប់គ្រងពលករមូលដ្ឋាន ក្រៅពីការដំណើរការ ដូចពោល ការគាំទ្រនិងឧបត្ថម្ភការរៀបចំសុខមាលភាពក្រៅពីច្បាប់ នៅតែជាការដែលបុគ្គលិកនឹងត្រូវចូលទៅនៅក្នុងគ្រឹះស្ថានប្រកបអាជីវកម្មដើម្បីណែនាំរូបបែបរបស់សុខមាលភាពផ្សេងៗ ដែលច្បាប់មិនបានកំណត់ទុកតែប្រសិន ជាគ្រឹះស្ថានប្រកបអាជីវកម្មណាមាន ភាពព្រមគ្រប់គ្រាន់ដ៏អាចរៀបចំអោយទៅតាមសេចក្តីត្រូវការរបស់និយោជិកបាន

ចំណែកទី 2 គឺជាចំណែកដែលទាក់ទងជាមួយគណៈកម្មការសុខមាលភាពដោយស៊ើបអង្កេតក្រៅពីការដែលគ្រប់គ្រឹះស្ថានប្រកបអាជីវកម្មមានការរៀបចំសុខមាលភាពអោយនិយោជិកគ្រប់កន្លែង តែរូបបែបឬវិធីការរៀបចំនឹងខុសគ្នាទៅតាមលក្ខណៈ វិធីការធ្វើការ ឬប្រភេទអាជីវកម្ម។ល។ របស់គ្រឹះស្ថានប្រកបអាជីវកម្មនោះ ទោះបីជានឹងមានការរៀបចំសុខមាលភាពអោយដល់ និយោជិកក៏ដោយ ប៉ុន្តែបញ្ហាការមានទំនាស់រវាងនិយោជកជាមួយនិយោជិកនៅតែច្បាស់ជារយៈពេលមួយបង្កើតអោយមានផលខូចខាតដល់គ្រឹះស្ថានប្រកបអាជីវកម្មសេដ្ឋកិច្ច និងការវិនិយោគទុនរបស់ប្រទេស

ដោយហេតុនេះព្រះរាជក្រឹតគ្រប់គ្រងពលករ ឆ្នាំ ព.ស.2541 ទើបបានមានបទបទបញ្ញត្តិអោយរៀបចំតាំងគណៈកម្មការសុខមាលភាពពលករឡើងតាមមាត្រា ៩២នៅការផ្តល់ពាក្យណែនាំការរៀបចំសុខមាលភាព ដើម្បីអោយការមានទំនាស់ផ្សេងៗ នៅគ្រឹះ ស្ថានប្រកបអាជីវកម្មថយចុះ និងដើម្បីអោយនិយោជិកមានគុណភាពជីវិតល្អឡើងទាំងនេះបានបទបញ្ញត្តិអោយមានគណៈកម្មការសុខមាលភាពពលករ ប្រកប ដោយ ប្រធាននាយកដ្ឋានក្រសួងពលករជាប្រធានគណៈកម្មការ កម្មការអ្នកតំណាងភាគី រាជរដ្ឋាភិបាល បួននាក់ កម្មការអ្នកតំណាងភាគីនិយោជក និងកម្មការអ្នកតំណាងភាគី និយោជិក ក្នុងមួយភាគី 5 នាក់ ដែលរដ្ឋមន្ត្រីតែងតាំងជាកម្មការ និងមន្ត្រីកម្មការ សុខមាលភាពនិងគ្រប់គ្រងពលករ ដែលរដ្ឋមន្ត្រីតែងតាំងជា លេខានុការ គណៈកម្មការ ដែលបានពោល មានអំណាចភារកិច្ចតាមដែលបានកំណត់ទុកនៅក្នុងមាត្រា 93 ដូចតទៅនេះ

**1** ស្នើរយោបើដល់រដ្ឋមន្ត្រីទាក់ទងជាមួយនយោបាយ ទិសដៅ និងវិធីការវាស់វែងផ្នែកសុខមាលភាពពលករ

**2** ស្នើរយោបល់ដល់រដ្ឋមន្ត្រីនៅក្នុងការចេញច្បាប់ក្រសួង ប្រកាស ឬរបៀបទាក់ទងការ រៀបចំសុខមាលភាពពលករនៅក្នុងគ្រឹះស្ថានប្រកបអាជីវកម្ម

**3** ផ្តល់ពាក្យណែនាំនៅក្នុងការរៀបចំសុខមាលភាពពលករសំរាប់គ្រឹះស្ថានប្រកប អាជីវកម្មគ្រប់ប្រភេទ

**4** តាមដានវាយតំលៃ និងរាយការផលការដំណើរការដល់រដ្ឋមន្ត្រី

**5** ចេញបទបញ្ជារអោយនិយោជកចំណាយប្រាក់សំណងពិសេសឬថ្លៃសំណង ពិសេសជំនួសការប្រាប់ទុកជាមុនតាមមាត្រា 120

**6** ប្រតិបត្តិការផ្សេងណាដែលតាមព្រះរាជបញ្ញត្តិនេះឬច្បាប់អោយជាអំណាចតួនាទី របស់គណៈកម្មការសុខមាលភាពពលករ ឬតាមដែលរដ្ឋមន្ត្រីប្រគល់អោយ

ចំណែកទី 3 ក្រៅពីការបញ្ញត្តិអោយមានការចាត់តាំងគណៈកម្មការសុខមាលភាពពលករហើយ ដើម្បីជាការទំនុកបំរុងឧបត្ថម្ភនិងដំណើរការអោយមានការរៀបចំសុខមាលភាព ដោយ ព្រះរាជ ក្រឹតគ្រប់គ្រងពលករឆ្នាំព.ស. 2541 កំណត់ទុកនៅក្នុងមាត្រា 96 អោយនិយោជករបស់ គ្រឹះស្ថាន ប្រកបអាជីវកម្មដែលមាននិយោជិកតាំងតែ **50** នាក់ឡើងទៅ ត្រូវរៀបចំ អោយមាន គណៈ កម្មការសុខមាលភាពនៅគ្រឹះស្ថានប្រកបអាជីវកម្ម ប្រកបដោយអ្នកតំណាងនិយោជិកយ៉ាង តិចប្រាំនាក់ ដោយទីតាំងកម្មការសុខមាលភាពនៅក្នុងគ្រឹះស្ថានប្រកបអាជីវកម្ម អោយមក ពីការជ្រើសរើស តាមមូលដ្ឋានគ្រឹះនិងវិធីការដែលអធិបតីកំណត់និងនៅក្នុងករណីដែល គ្រឹះស្ថានប្រកបអាជីវកម្មណារបស់និយោជកមានគណៈកម្មការនិយោជិកតាមច្បាប់ដោយ ពលករសម្ព័ន្ធភាពហើយ គណៈកម្មការនិយោជិកធ្វើតួនាទី ជាគណៈកម្មការ សុខមាលភាព នៅក្នុងគ្រឹះស្ថានប្រកបអាជីវកម្មតាមព្រះរាជក្រឹតនេះ

## គណៈកម្មការសុខមាលភាពក្នុងគ្រឹះស្ថានប្រកបអាជីវកម្ម

បំណងក្នុងការបង្កើតគណៈកម្មការសុខមាលភាពក្នុងគ្រឹះស្ថានប្រកបអាជីវកម្ម គឺជួយ លើកស្ទួយប្រព័ន្ធទ្វេភាគីដើម្បីផ្តល់ឱកាសអោយនិយោជិកបានពិភាក្សាជាមួយនិយោជកក្នុងការបង្កើតសុខមាលភាពផ្សេងៗដែលក្រៅពីច្បាប់កំនត់អោយបានយ៉ាងសមរម្យដល់គ្រឹះស្ថានប្រកបអាជីវកម្ម និងជាសុខមាលភាពដែលនិយោជិកខ្លួនឯងក៏ត្រូវការ។ វាមិនមែនជាការ បង្កើតឡើងតែភាគីខាងនិយោជក តែក៏មិនមែនជាការតម្រូវចិត្តភាគីខាងនិយោជិកដែរ វាគឺ ជាការផ្តល់ឱកាស

អោយនិយោជិកបានបង្ហាញនូវតំរូវការរបស់ខ្លួន និងបានទទួល ពត៌មាន ពីនិយោជកថាតើអាចបង្កើតសុខមាលភាពដែលខ្លួនស្នើរឡើងបានដែរឬទេវាជាការលើកកំ ពស់ដល់សម្ព័ន្ធភាពនិយោជិក និងបញ្ឈប់បញ្ហាការស្នើរសុំផ្សេងៗ បញ្ឈប់ជំលោះជាបឋម។

គណៈកម្មការសុខមាលភាពក្នុងគ្រឹះស្ថានប្រកបអាជីវកម្មដូចដែលបានពោលខាងលើ ច្បាប់បានកំនត់ភារៈកិច្ចតាមមាត្រា 97 ដូចតទៅ

(**1**) រួមពិភាក្សាជាមួយនិយោជកដើម្បីបង្កើតសុខមាលភាពដល់និយោជិក

(**2**) ផ្តល់ការប្រឹក្សានិងណែនាំដល់និយោជកក្នុងការបង្កើតសុខមាលភាព សម្រាប់ និយោជិក

(**3**) ត្រួតត្រា គ្រប់គ្រង ថែរក្សា ការរៀបចំសុខមាលភាពដែលនិយោជកបង្កើតសម្រាប់ និយោជិក

(**4**) លើកសំនើរការយល់ឃើញ និងទិសដៅក្នុងការរៀបចំសុខមាលភាពដែលជា ប្រយោជន៍សម្រាប់និយោជិកដល់គណៈកម្មការសុខមាលភាពពលករ។

ដូច្នេះគណៈកម្មការសុខមាលភាពក្នុងគ្រឹះស្ថានប្រកបអាជីវកម្ម ប្រៀបដូចជា ភ្នាក់ងារកណ្តាលសម្រាបពាំនាំនូវតំរូវការផ្នែកសុខមាលភាពរបស់និយោជិកមកអោយនិយោ ជកបានដឹង និងរួមផ្តល់ការប្រឹក្សាណែនាំនិងបូករួមទាំងការត្រួតពិនិត្យ ការរៀបចំ សុខមាលភាពក្នុងគ្រឹះស្ថានប្រកបអាជីវកម្ម ព្រោះច្បាប់ (មាត្រា **98**)បានចែងថា និយោជកត្រូវរៀបចំបង្កើតអោយមានការប្រជុំពិភាក្សាជាមួយគណៈកម្មការសុខមាលភាពក្នុងគ្រឹះស្ថានប្រកបអាជីវកម្មយ៉ាងតិចពាខែម្តងឬពេលកម្មការសុខមាលភាពក្នុងគ្រឹះស្ថានប្រកបអាជីវកម្មច្រើនជាងពាក់កណ្តាលនៃកម្មការទាំងអស់ ឬ ពលករស្នើរសុំដោយមានហេតុផលច្បាស់លាស់។

ការដែលច្បាប់កំនត់ដូច្នេះវាស្មើនិងការលើកស្ទួយ ឧបត្ថម្ភនិងដំណើរការអោយមាន ការបង្កើតសុខមាលភាពពលករឡើងក្នុងគ្រឹះស្ថានប្រកបអាជីវកម្ម ហើយប្រសិនបើ មិនមាន ដំណើរការទាំងនោះទេត្រូវមានទោសជាប់គុកហើយពិន័យជាប្រាក់ទៀត។

ក្រៅពីច្បាប់កំនត់អោយាមានគណៈកម្មការសុខមាលភាពពលករ រួមទាំងកំនត់អោយ មានគណៈកម្មការសុខមាលភាពក្នុងគ្រឹះស្ថានប្រកបអាជីវកម្ម ដើម្បីប្រកប អាជីវកម្ម ដែល ទាក់ទងនិងការរៀបចំសុខមាលភាពពលករក្នុងគ្រឹះស្ថានប្រកបអាជីវកម្ម ហើយព្រះរាជ ក្រិត្យការគ្រប់គ្រងពលករឆ្នាំព.ស.2541 និងមានបទបញ្ញត្តិដែលអោយតំលៃសំខាន់ទៅលើ គុណភាពជីវិតរបស់និយោជិកដែលបណ្តាលមកពីការផ្លាស់ប្តូរទីតាំងគ្រឹះស្ថានប្រកបអាជីវកម្មដោយមានចែងនៅក្នុងមាត្រា120 របស់ព្រះរាជក្រិត្យស្តីពីការគ្រប់គ្រងពលករឆ្នាំ ព.ស.2541 ធ្វើវិសោធនកម្មច្បាប់ដោយ ព្រះរាជក្រិត្យការគ្រប់គ្រងពលករ(ច្បាប់ទី **2**) ឆ្នាំព.ស. 2551

## ការដំណើរការករណីនិយោជកផ្លាស់ប្តូរទីកន្លែងគ្រឹះស្ថានប្រកបអាជីវកម្ម

ក្នុងករណីនិយោជកផ្លាស់ប្តូរទីតាំងប្រកបអាជីវកម្មទៅតាំងនៅទីកន្លែងផ្សេងដែលធ្វើអោយប៉ះពាល់ដល់ជីវភាពក្នុងការរស់នៅរបស់និយោជិក និយោជកត្រូវតែប្រាប់អោយ និយោជិកបានដឹងមុនយ៉ាងតិច **30** ថ្ងៃមុននិងផ្លាស់ប្តូរទីតាំង។ ប្រសិនបើនិយោជិកមិនចង់ ទៅធ្វើការនៅទីតាំងថ្មីទេ និយោជិកអាចសុំបញ្ចប់កិច្ចសន្យាជួលបានក្នុងរយះពេល **30**ថ្ងៃរាប់ចាប់តាំងពីថ្ងៃដែលនិយោជកបានជូនដំណឹង ឬថ្ងៃដែលនិយោជក ផ្លាស់ប្តូរទីតាំង ហើយ។ក្នុងករណីនេះ និយោជិកមានសិទ្ធិទទួលបានប្រាក់បំនាច់ការងារមិនតិចជាងប្រាក់ ដែលត្រូវទទួលបានតាមមាត្រា**118** ។ល។

ក្នុងករណីនិយោជកផ្លាស់ប្តូរទីតាំងប្រកបអាជីវកម្មទៅតាំងនៅទីកន្លែងផ្សេងដោយមិនបានប្រាប់និយោជិកជាមុន ដូចឃ្លាខាងលើនិយោជកត្រូវបង់ប្រាក់អោយនិយោជិក ជាប្រាក់ ពិសេសស្មើនិងប្រាក់ខែ ខែចុងក្រោយ ឬស្មើនិងប្រាក់ឈ្នួល 30ថ្ងៃចុងក្រោយ របស់ និយោជិកដែលទទួលតាមលទ្ធផលការងារដោយត្រូវគិតជាឯកត្តា។

និយោជកត្រូវបងប្រាក់អោយនិយោជិកក្នុងអំឡុងពេល៧ថ្ងៃបន្ទាប់ពីនិយោជិកស្នើរសុំបញ្ចប់កិច្ចសន្យាជួល។

ក្នុងករណីដែលនិយោជកមិនព្រមបងប្រាក់អោយនិយោជិកដូចចែងក្នុងឃ្លាទី**3** និយោជិកមានសិទ្ធិដាក់ពាក្យបណ្តឹងទៅគណៈកម្មការសុខមាលភាពពលករក្នុងអំឡុងពេល 30 ថ្ងៃដោយគិតចាប់តាំងពីថ្ងៃគ្រប់កំនត់ដែលនិយោជកត្រូវបង់។

គណៈកម្មការសុខមាលភាពពលករនិងពិចារ ណាហើយចេញបទបញ្ជាក្នុងអំឡុងពេល 60 ថ្ងៃដោយគិតចាប់តាំងពីថ្ងៃដែលទទួលបានពាក្យបណ្តឹង។

ពេលគណៈកម្មការសុខមាលភាពពលករពិចារណាហើយឃើញថា និយោជិកត្រូវទទួលបានប្រាក់ពិសេសពិតប្រាកដមែន គណៈកម្មការសុខមាលភាពពលករត្រូវចេញបទ បញ្ជាជាលាយលក្ខណ៍អក្សរអោយនិយោជកត្រូវតែបង់ប្រាក់អោយនិយោជិក ក្នុងអំឡុង ពេល 30 ថ្ងៃដោយគិតចាប់តាំងពីថ្ងៃដែលទទួលបានបទបញ្ជា។

ពេលគណៈកម្មការសុខមាលភាពពលករពិចារ ណាហើយឃើញថានិយោជិកមិនត្រូវទទួលបានប្រាក់ពិសេសទេនោះគណៈកម្មការសុខមាលភាពពលករត្រូវចេញបទបញ្ជាជាលាយលក្ខណ៍អក្សរអោយនិយោជកនិងនិយោជិកបានដឹង

បទបញ្ជាគណៈកម្មការសុខមាលភាពពលករចូលជាធរមាន លើកលែងតែនិយោជកឬ និយោជិកប្តឹងខទ្ទរជំទាស់និងបទបញ្ជាទៅតុលាការក្នុងអំឡុងពេល 30 ថ្ងៃដោយគិតចាប់តាំង ពីថ្ងៃដែលទទួលបានបទបញ្ជា តែប្រសិនបើភាគីនិយោជកជាអ្នកដាក់ពាក្យ បណ្តឹងទៅ តុលាការនិយោជកត្រូវដាក់លុយតំកល់នៅតុលាការ ស្មើនិងចំនួនដែលត្រូវបង់តាមបទបញ្ជាទើបអាចប្តឹងបាន។

និយោជិកមានសិទ្ធិដាក់ពាក្យបណ្តឹងទៅគណៈកម្មការសុខមាលភាពពលករអោយពិចារណាក្នុងអំឡុងពេល 30 ថ្ងៃដោយគិតចាប់តាំងពីថ្ងៃដែលនិយោជកគ្រប់កំនត់ត្រូវបង់ ដើម្បី អោយគណៈកម្មការសុខមាលភាពពលករអនុវត្តន៍តាមអំណាចតួនាទីបានយ៉ាងត្រឹមត្រូវ សមរម្យ មានប្រសិទ្ធិភាព ប្រកបដោយយុត្តិធម៌។ គណៈកម្មការសុខមាលភាពពលករ ទើបមានបទបញ្ជាអោយគណៈកម្មការសុខមាលភាពពលករតែងតាំងអនុគណៈកម្មការចំនួន២ដូចតទៅ

**1.** អនុគណៈកម្មការស៊ើបអង្កេតរកការពិតដើម្បីអនុវត្តន៍តួនាទីតាមព្រះរាជក្រិត្យ ការពារពលករឆ្នាំ ព.ស.2541 តាមបទបញ្ជាគណៈកម្មការសុខមាលភាពពលករ ទី**3**/ព.ស.**2548** ចុះថ្ងៃទី **21** ខែ កុម្ភៈ ឆ្នាំ ព.ស. **2541** មានអំណាចនិងតួនាទីដូចតទៅ

**(1)** ស៊ើបអង្កេតរកការពិតហើយប្រមូលភ័ស្តុតាងផ្សេងៗដែលទាក់ទង ក្នុងករណីមានការផ្លាស់ប្តូរទីតាំងប្រកបអាជីវកម្មតាមមាត្រា120របស់ព្រះរាជក្រិត្យស្តីពី ការការពារពលករ ព.ស.2548 ក្នុងទីក្រុងបាងកក ឬគ្រប់ទីកន្លែងទូទាំងព្រះរាជាណាចក្រ ក្នុងករណីខេត្តផ្សេងៗស្នើរសុំមកឬមានភាពចាំបាច់ចំពោះករណីខ្លះ។

**(2)** ពិចារណារួចស្នើរការយល់ឃើញតាម ខទី**(1)**មកអនុគណៈកម្មការ ជ្រើសរើសពលករ។

**(3)** អនុវត្តន៍តាមភារៈកិច្ចដែលគណៈកម្មការសុខមាលភាពពលករ ប្រគល់ អោយ។

**2.** អនុគណៈកម្មការជ្រើសរើសពលករ តាមបទបញ្ជារបស់កម្មការ សុខមាលភាព ពលករ ទី **2** / ព.ស.2548 ចុះថ្ងៃទី **21** ខែ កុម្ភៈ ឆ្នាំ ព.ស.2548 មានអំណាចនិងតួនាទីដូចតទៅ៖

**(1)** ពិចារណាជ្រើសរើសពលករ ជាអំណាចនិងភារៈកិច្ចរបស់គណៈកម្មការ សុខមាលភាពពលករ ព្រមទាំងរាយការណ៍និងស្នើរការយល់ឃើញទៅ គណៈកម្មការ សុខមាលភាពពលករ។

**(2)** អាចតែងតាំងគណៈកម្មការតាមភាពចាំបាច់ដើម្បីជួយអនុវត្តន៍ការងារ។

**(3)** អនុវត្តន៍តាមភារៈកិច្ចផ្សេងៗដែលគណៈកម្មការសុខមាលភាព ពលករប្រគល់អោយ។

## សុខមាលភាពពលករក្រៅពីច្បាប់កំនត់

សុខមាលភាពពលករក្រៅពីច្បាប់កំនត់ជាសុខមាលភាពដែលក្រុមសុខមាលភាពពលករបង្កើតឡើងដើម្បីអោយស្ថាប័នប្រកបអាជីវកម្មជ្រើសរើសបន្ថែម ដោយចែកជា ផ្នែកធំៗ ដូចតទៅ៖

**1.** សុខមាលភាពដែលផ្តោតលើការអភិវឌ្ឍន៍និយោជិក ដូចជា លើកស្ទួយការរៀន សូត្រ ទាំងនៅក្នុងនិងក្រៅពេលវេលាធ្វើការ ចាត់អោយមានសាលារៀននៅក្នុងរោងចក្រ ការបណ្តុះបណ្តាលចំនេះដឹងបន្ថែមទាក់ទងនិងការងារទាំងក្នុងនិងក្រៅកន្លែងធ្វើការ ការរៀប ចំអោយមានបណ្ណាល័យ ឬកន្លែងអានសៀវភៅ។ល។

**2.** សុខមាលភាពពលករដែលជួយសំរួលក្នុងការរស់ដូចជាការរៀបចំហាងទំនិញ លក់ក្នុងតំលៃសមរម្យ សហករណ៍ហាងទំនិញ កាផ្តល់ប្រាក់ជួយទំនុកបំរុងក្នុងពិធីផ្សេងៗ ដូចជាពិធីរៀបអាពាហ៍ពិពាហ៍ ពិធីបួស ពិធីបុណ្យសព ការរៀបចំឯកសណ្ឋានធ្វើការ ការរៀបចំកន្លែងស្នាក់នៅ ការរៀបចំឡានដឹកជញ្ជូន ប្រាក់បន្ថែម ជាដើម។

**3.** សុខមាលភាពពលករដែលជួយលើការសន្សំរបស់និយោជិកដូចជាសហករណ៍ សន្សំទ្រព្យ ប្រាក់បំរុងសំរាប់ការរស់នៅ។

**4.** សុខមាលភាពពលករដែលជួយអភិវឌ្ឍន៍សមាជិកគ្រួសាររបស់និយោជិកដូចជា ការរៀបចំទីកន្លែងថែរក្សាបុត្ររបស់និយោជិក ការជួយចេញថ្លៃព្យាបាលសមាជិក នៅក្នុង គ្រួសារ ការជួយបង់ថ្លៃចូលរៀនអោយបុត្ររបស់និយោជិក ការធានារ៉ាប់រងជីវិតអោយ និយោជិក

**5.** សុខមាលភាពដែលលើកស្ទួយភាពគង់វង្សនៅពេលអនាគតរបស់និយោជិក ដូចជា ប្រាក់បំណាច់ ប្រាក់រង្វាន់ចំពោះនិយោជិកធ្វើការ យូរឆ្នាំនិងអាចទិញភាគហ៊ុន របស់ក្រុមហ៊ុន បាន ប្រាក់ជំនួយឈាបនកិច្ច(ការបូជាសព) ប្រាក់កំចីដើម្បីសុខមាលភាពទីកន្លែងស្នាក់នៅ

**6.** សុខមាលភាពពលករក្នុងការសំរាកកម្សាន្ត និង សុខភាពអនាម័យទស្សនៈ កិច្ចសិក្សា ការប្រកួតកីឡា ការរៀបចំពិធីជប់លៀងនិយោជិក ការផ្តល់ចំនេះដឹងទាក់ទង ជាមួយសុខភាពអនាម័យ។

ភារៈកិច្ចក្នុងការលើកស្ទួយសុខមាលភាពក្រៅពីច្បាប់កំនត់ដូចមានចែងខាងលើនេះ នាយកដ្ឋានសុខមាលភាពនិងការគ្រប់គ្រងពលករបានពិភាក្សាជាមួយនាយកដ្ឋានពន្ធដាដើម្បីស្នើរសុំលើកលែងភាសីចំពោះសុខមាលភាពដែលនិយោជកបានរៀបចំអោយនិយោជិក ចំនួន 13 ចំនុចតែត្រូវវិភាគមើលថាទាំង 13ចំនុចនេះតើចំនុចណាខ្លះដែលជាអត្ថប្រយោជន៍ បន្ថែមដល់និយោជិក ហើយចំនុចណាខ្លះដែលមិនមែន ជាអត្ថប្រយោជន៍ បន្ថែមដល់និយោជិក ហើយតើសុខមាលភាពអ្វីខ្លះដែលបានទទួលហើយ មិនចំបាច់យក មកគណនាចេញជាទឹកលុយ គឺអាចប៉ាន់ប្រមាណបានតាមមាត្រា **40(1)** ដែលបានកំនត់ ក្នុងការប្រមូលចំនូលរបស់រដ្ឋ។សុខមាលភាពទាំង **13** ចំនុចគឺ

**1**. អាហារ ភេសជ្ជៈ កន្លែងទទួលទានអាហារក្នុងពេលធ្វើការ

**2**. ថវិការជួយទំនុកបំរុងការសិក្សារបស់កូននិយោជិក

**3**. វត្ថុអនុស្សាវរីយ៍ក្នុងថ្ងៃខួបកំនើតនិយោជិក

**4**. កន្លែងស្នាក់នៅដែលនិយោជករៀបចំអោយ

**5**. ដំណើរទស្សនាចរទៅតំបន់ទេសចរណ៍ផ្សេងៗដែលនិយោជកជាអ្នកនាំ

**6**. រថយន្តដឹកជញ្ជូននិយោជិក

**7**. រង្វាន់ដែលគិតតាមអាយុកាលនៃការធ្វើការ

**8**. ប្រាក់បំណាច់ ប្រាក់សោធន ប្រាក់សំណងដែលត្រូវបង់ពាក់កណ្តាលពេលនិយោជិកលាឈប់ពីការងារ

**9.** ធានារ៉ាប់រងទាំងជីវិតនិងសុខភាពរបស់និយោជិក

**10.** មជ្ឈមណ្ឌលចិញ្ចឹមក្មេងក្នុងកន្លែងប្រកបអាជីវកម្ម

**11.** សាលារៀនក្នុងរោងចក្រ

**12.** គំរោងរោងចក្រសស្អាតគ្មានថ្នាំញៀន

**13.** ការការពារនិងទប់ស្កាត់មេរោគអេដស៍

ក្រោយមកនាយកដ្ឋានពន្ធដាបានឆ្លើយតបនិងនាយកដ្ឋានសុខមាលភាពនិងការគ្រប់គ្រងពលករដូច្នេះថា៖

ក្នុងករណីសុខមាលភាពឬអត្ថប្រយោជន៍ដែលនិយោជិកបានទទួល ហើយនាយកដ្ឋានពន្ធដាចាត់ទុកថាជាអត្ថប្រយោជន៍ដែលវាចូលទៅក្នុងលក្ខណៈជាថវិការគ្លូតែវាយតំលៃនិងត្រូវរួមយកមកគណនាជាភាស៊ីបុគ្គលធម្មតាបាន មានដូចជា ការរៀបចំបណ្តុះបណ្តាលនិយោជិកដោយមិនគិតប្រាក់ ថវិការជួយទំនុកបំរុងការ សិក្សាដល់ កូននិយោជិក កន្លែងស្នាក់នៅដែលនិយោជករៀបចំអោយដោយមិនអស់ថ្លៃជួល ការរៀបចំ ដំណើរទស្សនាចរទៅតំបន់ទេសចរណ៍ផ្សេងៗដល់និយោជិក រង្វាន់ដែលប្រគល់អោយ និយោជិក មានអាយុច្រើន ថ្លៃធានារ៉ាប់រងជីវិតនិងសុខភាព ការរៀបចំអោយមានមជ្ឈមណ្ឌល ចិញ្ចឹមក្មេងនិងថែរក្សាបុត្ររបស់និយោជិក នឹងប្រាក់បំណាច់ ប្រាក់សោធន ឬប្រាក់សំណង ដែលត្រូវបង់តែម្តងគត់ពេលនិយោជិកលាឈប់ពីការងារ។

ក្នុងករណីសុខមាលភាពឬអត្ថប្រយោជន៍ដែលនិយោជិកបានទទួលពីនិយោជក ហើយមិនចាត់ទុកជាអត្ថប្រយោជន៍បន្ថែមដែលនិយោជិកត្រូវយកមកគណនាជាភាស៊ីបុគ្គលធម្មតាបាន ដូចជា រថយន្តដឹកជញ្ជូននិយោជិក ការរៀបចំអោយមានការសិក្សាក្រៅម៉ោង គំរោង រោងចក្រសស្អាតគ្មានថ្នាំញៀន ការការពារនិងទប់ស្កាត់មេរោគអេដស៍ វត្ថុអនុស្សាវរីយ៍ក្នុងថ្ងៃ ខួបកំនើតនិយោជិក។

**ពត៌មានលំអិតស្តីអំពីការដំណើរការការងារផ្នែកសុខមាលភាពពលករ**

## 1. ការផ្តល់សេវាចិញ្ចឹមកុមារនៅមជ្ឈមណ្ឌលចិញ្ចឹមកុមារសាខាសិរិនថនវិទ្យាល័យក្រោមព្រះរាជឧបត្ថម្ភ

ដោយសាររដ្ឋាភិបាលមាននយោបាយជួយឧបត្ថម្ភក្នុងការបង្កើតមជ្ឈមណ្ឌលចិញ្ចឹមកុមារវ័យមុនពេលចូលរៀនតាមស្តង់ដាររបស់សហគមន៍ និងសហគ្រាស អគ្គនាយកដ្ឋាន សុខុមាលភាពនិងគ្រប់គ្រងពលករបានដើរតួរជាអង្គភាពសំខាន់ក្នុងការលើកស្ទួយសុខមាលភាពពលករបន្ថែមលើអ្វីដែលច្បាប់បានកំណត់។ អគ្គនាយកដ្ឋានសុខុមាលភាព និងគ្រប់គ្រង ពលករក៏បានកំណត់ឲ្យសហគ្រាសអាជីកម្មផ្តោតការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍកុមារជាចំបង ជាពិសេសកុមារដែលជាកូនរបស់ពលករ។ ហេតុនេះហើយទើបកំណត់ឲ្យមានការ បង្កើតមជ្ឈមណ្ឌលចិញ្ចឹមកុមារសាខាសិរិនថនវិទ្យាល័យក្រោមព្រះរាជឧបត្ថម្ភនៅខេត្តនគរបឋម នៅព.ស **2535** និងនៅខេត្តសមុទ្រប្រាកាននៅ ព.ស **2544** ក្នុងបំណងដើម្បីឲ្យកូន ចៅរបស់ពលករនៅក្នុងខេត្តទាំងពីរបានចូលមកទទួលការចិញ្ចឹម អភិវឌ្ឍន៍ផ្លូវកាយ ផ្លូវចិត្ត សតិបញ្ញា អារម្មណ៍និងសង្គម។ ការអភិវឌ្ឍផ្នែកទាំងនេះ ជាការកសាងមូលដ្ឋានគ្រឹះ ផ្នែកគំនិតនិងរាងកាយដល់កុមារវ័យមុនចូលសិក្សា ដើម្បីឲ្យពួកគេបានត្រៀមខ្លួនរួចជាស្រេច ក្នុងការសិក្សានៅសាលារៀន ថែមទាំងដើម្បីជួយកាត់បន្ថយបន្ទុកការងាររបស់ អាណាព្យាបាល កុមារ។ ទន្ទឹមគ្នានេះដែរ សេវាកម្មចិញ្ចឹមកុមារក្នុង មជ្ឈមណ្ឌលបានជួយ ឲ្យពលករពុំមានកង្វល់ខ្វល់ខ្វាល់ក្នុងការមើលថែរកូនចៅរបស់ខ្លួន។ ដោយសារតែមានអ្នក ជួយចិញ្ចឹមបីបាច់កូនចៅ ពលករមានពេលគ្រប់គ្រាន់ដើម្បីធ្វើការងាប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធិភាព ដែលទាំងនេះបានជួយឲ្យអាជីវកម្មរបស់និយោជកមានការរីកចម្រើន មាន លទ្ធភាពរកប្រាកចំណូលបានច្រើន រីឯពលករវិញអាចទទួលប្រាក់កម្រៃខ្ពស់ និងគុណភាព ជីវិតដ៏

ល្អប្រសើរ។ គោលបំណងនៃមជ្ឈមណ្ឌលចិញ្ចឹមកុមារ គឺអនុញ្ញាតិឲ្យកុមារដែលមាន អាយុ ពី 3 ទៅ 6 ឆ្នាំចំនួន 1300 នាក់មកទទួលការចិញ្ចឹមបីបាច់ ក្នុង មជ្ឈមណ្ឌលចិញ្ចឹម កុមារទាំងពីរកន្លែង ។ ដើម្បីឲ្យការគ្រប់គ្រងមជ្ឈមណ្ឌលចិញ្ចឹមកុមារ ដំណើរការបានល្អមាន ប្រសិទ្ធិភាពខ្ពស់ អគ្គនាយកដ្ឋានសុខុមាលភាពនិងគ្រប់គ្រងពលករបានចេញលិខិតឧទ្ទេសនាមតែងតាំងគណៈទីប្រឹក្សា និងគណៈកម្មការមជ្ឈមណ្ឌលចិញ្ចឹមកុមារសាខាសិរិនថនវិទ្យាល័យ រួមមានគណៈកម្មការទទួលបន្ទុកតាមផ្នែកផ្សេងៗ ដែលមានតួនាទីផ្តល់យោបល់ទាក់ទង នឹងការ ដំណើរការ និងរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការចិញ្ចឹមកុមារក្នុងមជ្ឈមណ្ឌល។ ចំណាយ ផ្សេងៗក្នុងការដំណើរការគ្រប់គ្រងមជ្ឈមណ្ឌលទាំងពីរកន្លែងមួយផ្នែកបានមកពីថវិការរបស់ អគ្គនាយកដ្ឋានដែលយកមកប្រើប្រាស់សម្រាប់ប្រាក់ខែបុគ្គលិក សម្ភារៈសារពើភ័ណ្ឌ និងសំណង់អគារផ្សេងៗ រីឯមួយផ្នែកទៀតបានមកពីការជួយឧបត្ថម្ភពីសំណាក់ អាណាព្យាបាលកុមារតាមរយៈមូលនិធិមជ្ឈមណ្ឌលចិញ្ចឹមកុមារសាខាសិរិនថនវិទ្យាល័យ ដែលថវិការនេះត្រូវបានយកមកប្រើប្រាស់សម្រាប់អាហារថ្ងៃត្រង់កុមារ និងចំណាយ ផ្សេងៗ ទៀតដែលគ្មាននៅក្នុងខ្ទង់ចំណាយថវិការរបស់អគ្គនាយកដ្ឋាន។

## 2. ការផ្តល់សេវាប្រាក់កំចីដល់ពលករ

ការពីថ្ងៃទី **20** ខែមិថុនា ឆ្នាំព**.**ស**.**2538 គណៈរដ្ឋមន្ត្រីបានអនុម័តគោលការណ៍គម្រោងបង្កើតមូលនិធិប្រាក់កំចីសម្រាប់ពលករក្នុងរូបបែបប្រាក់បង្វិលដែលមានចែងក្នុងព្រះរាជក្រឹតស្តីអំពីប្រាក់ទុនបំរុង ព**.**ស **2491** ដើម្បីជា ប្រភពធនធានហិរញ្ញវត្ថុសម្រាប់ពលករខ្ចីទៅប្រើប្រាស់។ កំចីប្រាក់តាមរយៈ សហករណ៍ ក្នុងសហគ្រាស បានធ្វើឲ្យពលករ និងគ្រួសារមានលទ្ធភាពដោះស្រាយ សងបំណុលក្រៅ ប្រព័ន្ធបាន លើសពីនេះ វាក៏អាចជួយឲ្យជីវភាពពលករមានស្ថេរភាពផងដែរ។ តាមប្រកាស របស់ក្រសួងការងារនិងសុខមាលភាពសង្គម ប្រាក់ដែលពលករខ្ចីមានអត្រាការ ប្រាក់ មិនតិចជាងអត្រាការប្រាក់នៅតាមបណ្តាធនាគារពាណិជ្ជកម្មឡើយ ។

### ការគ្រប់គ្រងប្រាក់មូលនិធិសម្រាប់ពលករ

មូលនិធិសម្រាប់ពលករត្រូវបានគ្រប់គ្រងដោយគណៈកម្មការដូចមានចែងនៅក្នុងជំពូកទី 2 មាត្រា **10** ក្នុងច្បាប់ស្តីអំពីមូលនិធិសម្រាប់ពលករ ព**.**ស **2543** របស់ក្រសួងការងារ និងសុខមាលភាពសង្គម។ គណៈកម្មការនេះមានភារកិច្ចដូចមានចែងក្នុងមាត្រា **11** ដូចតទៅ:

មាត្រា **10** មានការចាត់តាំងគណៈកម្មការមួយដែលមានឈ្មោះថា " គណៈកម្មការមូលនិធិពលករ" ក្នុងនោះមានរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច ជាប្រធាន គណៈ កម្មការ តំណាងក្រសួងសេដ្ឋកិច្ច តំណាងការិយាល័យហិរញ្ញវត្ថុ តំណាងការិយាល័យធានា រ៉ាប់រងសង្គម តំណាងនាយកដ្ឋានសេវនកម្មគណនេយ្យសហករណ៍ជាសមាជិក

ក្រៅពីនេះ មានតំណាងភាគីនិយោជកចំនួន៣នាក់−ពលករចំនួន៣នាក់ អ្នកជំនាញការ នាយកដ្ឋាន សុខមាលភាពពលករជាសមាជិកនិងជាលេខាធិការ។

អ្នកជំនាញការត្រូវបានជ្រើសរើសនិងតែងតាំងដោយរដ្ឋមន្ត្រីដោយពិចារណាលើចំណេះដឹងជំនាញផ្នែក គណនេយ្យ ធនាគារ ហិរញ្ញវត្ថុ និងសហករណ៍។

មាត្រា **11** គណៈកម្មការមានតួនាទីដូចខាងក្រោម:

1. កំណត់នយោបាយ ត្រួតពិនិត្យ និងទទួលខុសត្រូវការគ្រប់គ្រងការងារមូលនិធិ។
2. អនុម័តកំចីប្រាក់
3. ធ្វើរបាយការណ៍ស្តីពីលទ្ធផលការដំណើរការជូនរដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រី
4. គាត់តែងបទបញ្ជាផ្ទៃក្នុង និងច្បាប់ក្នុងការគ្រប់គ្រងប្រាក់មូលនិធិ
5. អនុម័តប្រាក់ចំណាយក្នុងការងារគ្រប់គ្រងមូលនិធិទៅតាមភាពចាំបាច់
6. វិនិច្ឆ័យ ចង្អុលបង្ហាញបញ្ហាក្នុងការអនុវត្តការងារ
7. ធ្វើការងារដទៃទៀតតាមដែលមានចែងក្នុងបទបញ្ជាឬតាមដែលរដ្ឋមន្ត្រី ប្រគល់ជូន

ក្រៅពីការអនុវត្តការងារតាមមាត្រា **10** គណៈកម្មការមានសិទ្ធិក្នុងការតែងតែង អនុគណៈកម្មការដើម្បីធ្វើការអ្វីមួយតាមភាពចាំបាច់ ។ ដូចមានចែងក្នុងមាត្រា **14** គណៈកម្មការអាចតែងតាំងអនុគណៈកម្មការចំនួន២ទៀត គឺ អនុគណៈកម្មការ ពិចារណា ប្រាក់កំចីមូលនិធិពលករ និងអនុគណៈកម្មការលើកស្ទួយ និងអភិវឌ្ឍន៏មូលនិធិពលករ។ អនុគណៈកម្មការទាំង 2 នេះមានតួនាទីដូចតទៅ:

### អនុគណៈកម្មការពិចារណាប្រាក់កំចីមូលនិធិពលករ

1. ពិចារណាសំនើសុំប្រាក់កំចីមូលនិធិ ដោយផ្អែកទៅលើគោលការណ៍ច្បាប់ ស្តីពីមូលនិធិពលកររបស់ក្រសួងការងារនិងសុខមាលភាពសង្គម។
2. បញ្ជូនលទ្ធផលនៃការពិចារណាទៅកាន់ថ្នាក់ដឹកនាំដែលមានសិទ្ធិអនុម័ត លើការខ្ចីប្រាក់។
3. អនុម័តប្រាក់កំចីក្នុងចំនួនទឹកប្រាក់ដែលគណៈកម្មការកំណត់។

## 3. ការលើកស្ទួយការបង្កើតមជ្ឈមណ្ឌលចិញ្ចឹមកុមារក្នុងសហគ្រាស និងសហគមន៍

អគ្គនាយកដ្ឋានសុខុមាលភាពនិងគ្រប់គ្រងពលករបានផ្តោតការយកចិត្តទុកដាក់ក្នុងការបង្កើតមជ្ឈមណ្ឌលចិញ្ចឹមកុមារក្នុងសហគ្រាស និងសហគមន៍ ដោយមានការសហករណ៍ ពីស្ថាប័នដែលពាក់ព័ន្ធផងដែរ។ នៅថ្ងៃទី 28 ខែធ្នូ ព.ស 2547 អគ្គនាយកដ្ឋានបានទទួល ការជ្រោមជ្រែងសហការណ៏ពី ក្រសួងការងារ ក្រសួងអភិវឌ្ឍសង្គមនិងស្ថេរភាពពលរដ្ឋ ក្រសួងមហាផ្ទៃ ក្រសួងអប់រំ និងក្រសួងសុខាភិបាល ដែលក្នុងនោះទំនួលខុសត្រូវរបស់ អន្តរក្រសួង គឺផ្តោតទៅលើការផ្សព្វផ្សាយលើកស្ទួយ និងជំរុញឲ្យសហគ្រាស រោងចក្រ

បង្កើតមជ្ឈមណ្ឌលចិញ្ចឹមកុមារផ្ទៃក្នុង ក្នុងគោលបំណងជួយ កាត់បន្ថយបន្ទុកក្នុងការ ចិញ្ចឹមបីបាច់កុមាររបស់ពលករ និងជួយអភិវឌ្ឍកុមារទាំងផ្លូវកាយនិងផ្លូវចិត្ត ពោលគឺជួយឲ្យ កុមារមានគុណភាពជីវិតដ៏ល្អប្រសើរ។

## 4. ការអនុវត្តការងារដើម្បីទប់ស្កាត់បញ្ហាថ្នាំញៀននៅក្នុងកន្លែងធ្វើការ ដោយរៀបចំឲ្យមាន គម្រោងលើកស្ទួយភាពរឹងមាំនៅក្នុងទីកន្លែងប្រកបអាជីកម្ម។

អគ្គនាយកដ្ឋានសុខុមាលភាពនិងគ្រប់គ្រងពលករមានតួនាទីត្រួតពិនិត្យនិងគ្រប់គ្រងពលករ ជុំរុញឲ្យនិយោជកនិងពលករអនុវត្តការងារតាមព្រះរាជក្រឹតគ្រប់គ្រងព.ស **2541** និងជួយឲ្យសហគ្រាស ប្រកបអាជីវកម្មគ្រប់កន្លែងបានយល់ជ្រួតជ្រាបពីវិធីសាស្រ្តទប់ស្កាត់និងការពារបញ្ហាថ្នាំញៀន ព្រមទាំងធានានូវការអនុវត្តនៃព្រះរាជក្រឹតទប់ស្កាត់និងបង្រ្កាប គ្រឿងញៀនព.ស **2519** ច្បាប់វិសោធនកម្ម (ច្បាប់ទី៣) ព.ស **2543** ប្រកបដោយប្រសិទ្ធិភាពខ្ពស់។ អគ្គនាយកដ្ឋានសុខុមាលភាពនិងគ្រប់គ្រងពលករបានចុះហត្ថលេខាលើប្រកាសអន្តរអគ្គនាយកដ្ឋានជាមួយអគ្គនាយកដ្ឋានទប់ស្កាត់និងបង្រ្កាបគ្រឿងញៀន ក្នុងគោលបំណងដើម្បី សហការគ្នាទប់ស្កាត់ និងដោះស្រាយបញ្ហាគ្រឿងញៀន។ភារកិច្ចនេះ ត្រូវបានទទួលការ ឧបត្ថម្ភគាំទ្រផ្នែកថវិការពីសំណាក់ការិយាល័យគណៈកម្មការទប់ស្កាត់និងបង្រ្កាបគ្រឿងញៀន( ប៉.ប៉.ស)។ លើសពីនេះទៅទៀត ដើម្បីឲ្យមានការចូលរួមសហការណ៏ពី សំណាក់សហគ្រាសប្រកបអាជីវកម្មក្នុងការទប់ស្កាត់ និងដោះស្រាយបញ្ហាគ្រឿងញៀន អគ្គនាយកដ្ឋានសុខុមាលភាពនិងគ្រប់គ្រងពលករបានបង្កើតគម្រោងលើកស្ទួយភាពរឹងមាំនៅតាមទីកន្លែងប្រកបអាជីកម្ម ដើម្បីផ្សព្វផ្សាយយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន។ គម្រោងទាំងនោះរួមមាន គម្រោងរោងចក្រព៏ណបៃតង គម្រោងកីឡាក្នុងរោងចក្រ គម្រោងវិលត្រឡប់មកកាន់ជីវិតថ្មី គម្រោងលើកស្ទួយទីកន្លែង ប្រកបអាជីវកម្មឲ្យ ក្លាយជាមជ្ឈមណ្ឌលផ្តល់ចំណេះដឹងដើម្បីទប់ស្កាត់ និងដោះស្រាយបញ្ហាគ្រឿងញៀន ជាដើម។

## 5. ការអនុវត្តការងារដើម្បីទប់ស្កាត់ការរាលដាលនិងដោះស្រាយជំងឺអេដស៍

ក្នុងសហគ្រាសអេដស៍គឺជាបញ្ហាដែលអាចកើតមានឡើង នៅក្នុងសហគ្រាស ហើយក៏ជាបញ្ហាដែលត្រូវយកចិត្តទុកដាក់បំផុតស្របតាមតាមគោលការណ៍ប្រតិបត្តិចំពោះបញ្ហាជំងឺអេដស៍ និងការងារ សកសរបស់អង្គការពលកម្មពិភពលោក។ ការយកចិត្តទុកដាក់ ចំពោះបញ្ហាជំងឺអេដស៍ នេះធ្វើឡើង ដោយសារតែជំងឺអេដស៍មិនត្រឹមតែផ្តល់ ផលប៉ះពាល់ដល់ សុខភាពពលករ ជាលក្ខណៈបុគ្គលប៉ុណ្ណោះទេ តែវាមានផលប៉ះពាល់ដល់ពិភពការងារ គុណភាពជីវិតពលករ និងអាជីវកម្មរបស់សហគ្រាសទៀត។

### អគ្គនាយកដ្ឋានសុខុមាលភាពនិងគ្រប់គ្រងពលករបានចាត់វិធានការប្រយុទ្ធប្រឆាំងនឹង ជំងឺអេដស៍ដូចតទៅនេះ

**1.** ដំណើរការការងារដោយប្រើប្រាស់ថវិការប្រចាំឆ្នាំរបស់របស់អគ្គនាយកដ្ឋាន សុខុមាលភាពនិងគ្រប់គ្រងពលករ ដោយក្នុងនោះនាយកដ្ឋានសុខុមាលភាពពលកម្មបានបញ្ជាតាមខ្សែបណ្តោយឲ្យការិយាល័យលើកស្ទួយគុណភាពការអប់រំ និងគ្រឹះស្ថាន ទទួលស្គាល់គុណភាពមណ្ឌលសុខភាពគ្រប់ខេត្តក្រុងរៀបចំសកម្មភាពដើម្បីប្រយុទ្ធប្រឆាំង នឹងជំងឺអេដស៍នៅក្នុងសហគ្រាស។

**2.** ការដំណើរការការងារក្រោមការជួយឧបត្ថម្ភពីមូលនិធិពិភពលោកត្រូវបានធ្វើឡើង ដោយមានការចេញប្រកាសរបស់ក្រសួងការងារស្តីអំពីវិធីសាស្ត្រការពារ និងប្រឆាំងជំងឺ អេដស៍ ក្នុងសហគ្រាស តាមរយៈការអនុវត្តគម្រោងនៅតាមតំបន់ផ្សេងៗដោយយកគំរូតាម គម្រោងរបស់ខេត្តរ៉ាយ៉ង។ ក្នុងការអនុវត្តគម្រោង អគ្គនាយកដ្ឋានសុខុមាលភាពនិង គ្រប់គ្រងពលករ អគ្គនាយកដ្ឋានប្រយុទ្ធប្រឆាំងជំងឺអេដស៍ និងសមាគមន៍ពាណិជ្ជកម្ម ចំរុះថៃដើម្បីប្រឆាំងជំងឺអេដស៍ បានចុះហត្ថលេខារួមគ្នាលើកិច្ចសហប្រតិបត្តិការក្នុងការ ដំណើរការគម្រោងទប់ស្កាត់និងប្រឆាំងនឹងជំងឺអេដស៍ក្នុងសហគ្រាស ក្រោមការឧបត្ថម្ភថវិការពីមូលនិធិពិភពលោក។ ការអនុវត្តគម្រោងទាំងនេះធ្វើឡើងស្របតាមគោល នយោបាយ អនុសាសន៍ ការត្រួតពិនិត្យ និងការវាយតម្លៃលទ្ធផលការងារពីសំណាក់គណៈ កម្មការអភិវឌ្ឍនយោបាយទប់ស្កាត់ និងប្រយុទ្ធប្រឆាំងជំងឺអេដស៍ដែលជាគណៈកម្មការ ពហុភាគី ដោយមានអគ្គនាយកអគ្គនាយកដ្ឋានសុខុមាលភាពនិងគ្រប់គ្រងពលករ ជាប្រធានគណៈកម្មការ ។ ការអនុវត្តគម្រោងក្រោមការជួយឧបត្ថម្ភពីមូលនិធិពីភពលោក មានសមាគមន៏TBCA ជាអ្នកទទួលខុសត្រូវគ្រប់គ្រងគម្រោង ចំណែកឯអគ្គនាយក អគ្គនាយកដ្ឋានសុខុមាលភាពនិងគ្រប់គ្រងពលករមានតួនាទីជួយគាំទ្រការងារ និងចូលរួម ក្នុងសកម្មភាពគម្រោង។

## 6. គម្រោងសាលារៀនក្នុងសហគ្រាសដើម្បីផ្តល់ឱកាសនិងជម្រើសដល់អ្នកពលករឲ្យទទួល

បាននូវចំណេះដឹងកាន់តែខ្ពស់ អគ្គនាយកអគ្គនាយកដ្ឋានសុខុមាលភាព និងគ្រប់គ្រងពលករ បានសហការណ៏ជាមួយនាយកដ្ឋានអភិវឌ្ឍន៏ជំនាញពលករ ការិយាល័យការសិក្សា ក្រៅប្រព័ន្ធ នៃសាកលវិទ្យាល័យសុខោទ័យធម្មធិរាជ សភាឧស្សាហកម្មនៃប្រទេសថៃ និងនិយោជកដែលជាម្ចាស់សហគ្រាសក្នុងការបង្កើតសាលារៀននៅក្នុងសហគ្រាស⁻ រោងចក្រ។ គម្រោងនេះបានជួយអភិវឌ្ឍចំណេះដឹងរបស់ពលករ និងជុំរុញឲ្យនិយោជក យល់ពីសារប្រយោជន៏នៃការសិក្សារបស់ពលករ។

## 7. ការលើកស្ទួយសុខុមាលភាពថវិការ

និងការគ្រប់គ្រង ដើម្បីលើកស្ទួយឲ្យពលករបានទទួលការសិក្សាសម្រាប់អនាគតពួកគេ និងដើម្បីកាត់បន្ថយការជំពាក់បំណុលឈ្នួញកណ្តាល ព្រមទាំងដើម្បីជួយឲ្យពួកគេមានស្ថេរភាពផ្នែកថវិការ អគ្គនាយកដ្ឋានសុខុមាលភាពនិង គ្រប់គ្រងពលករ បានលើកស្ទួយឲ្យមានការបង្កើតសហករណ៏សន្សំប្រាក់ ទាំងក្នុងសហគ្រាសរដ្ឋនិងឯកជន។ ការងារនេះបានទទួលការសហការពីសំណាក់ អង្គភាពដែលទាក់ទងជាច្រើនដូចជា នាយកដ្ឋានលើកស្ទួយសហករណ៏សហគមន៏ សហករណ៏សន្សំប្រាក់នៃប្រទេសថៃ សម្ព័ន្ធសហករណ៏នៃប្រទេសថៃ ឬនាយកដ្ឋាន ត្រួតពិនិត្យគណនេយ្យសហករណ៏។ ក្នុងគម្រោងនេះ នាយកដ្ឋានសុខុមាលភាព ការងារផ្តល់ នូវថវិការកំចី តាមរយ:សហករណ៏សន្សំប្រាក់ដោយបង្កើតឲ្យមានមូលនិធិសម្រាប់ពលករ ស្របតាមការអនុម័តរបស់គណ:រដ្ឋមន្ត្រី ។ នៅឆ្នាំ ព.ស. 2538 មូលនិធិនេះមានទុនបង្វិលចំនួន 100 លានបាតរហូតដល់បច្ចុប្បន្នទុនបង្វិលមានការកើនឡើងដល់ 290 លាន។

## 8. ការលើកស្ទួយមូលនិធិប្រាក់ទុនបំរុងក្នុងសហគ្រាស

ជាការការលើកស្ទួយឧបត្ថម្ភដល់និយោជកក្នុងការរៀបចំសេវាសុខមាលភាពជូនពលករ បន្ថែមលើអ្វីដែលច្បាប់កំណត់។ សេវានេះលើកស្ទួយជំរុញឲ្យមានការសន្សំប្រាក់ក្នុងវ័យធ្វើការ និងដើម្បីយកប្រាក់នោះ មកធ្វើជាប្រាក់ទុនដោយជ្រើសរើសក្រុមហ៊ុនមកធ្វើជាអ្នកតំណាង យកប្រាក់នោះទៅ វិនិយោគទុន។ការវិនិយោគបែបនេះបានមកពីកិច្ចសហប្រតិបត្តិការរវាងនិយោជក និងពលករដែលភាគីទាំងពីរបាននាំយកប្រាក់មកបង់សន្សំទុកជាប្រាក់ទុនមូលនិធិ។ ប្រាក់ទុនមូលនិធិនេះមានគោលបំណងជួយឲ្យពលករបានសន្សំប្រាក់ទុកសម្រាប់ប្រើប្រាស់នៅពេលពួកគេចូលនិវត្តន៍។ បើសហគ្រាសណាចាប់អារម្មណ៍នឹងមូលនិធិប្រាក់ទុននេះ សូមមេត្តាទាក់ទងសុំពត៌មានលំអិតពីការិយាល័យគណៈកម្មការគ្រប់គ្រងភាគហ៊ុន និងទីផ្សារភាគហ៊ុនបាន។

## 9. ការលើកស្ទួយការចិញ្ចឹមកូនដោយទឹកដោះម្តាយក្នុងសហគ្រាស

vអគ្គនាយកដ្ឋាន សុខុមាលភាពនិងគ្រប់គ្រងពលករក្នុងនាមជាអ្នកមើលការខុសត្រូវលើសហគ្រាស បានជំរុញឲ្យនិយោជិកគ្រប់អនុវត្តន៍តាមព្រះរាជក្រឹតគ្រប់គ្រងពលករព.ស 2541។ ជាពិសេសក្នុងការគ្រប់គ្រងពលករនី គឺកំណត់ឲ្យពលករនីដែលមានគត៌មានសិទ្ធិ សុំច្បាប់សម្រាកដើម្បីសម្រាលកូន ម្តងមិនលើសពី 90 ថ្ងៃ ដោយទទួលបានប្រាក់ឈ្នួល ជាធម្មតា។ ទោះបីយ៉ាងណាក៏ដោយក៏នៅមានសហគ្រាសមួយចំនួនបានល្មើសមិនព្រម ផ្តល់ជូនសិទ្ធិឲ្យពលករតាមច្បាប់កំណត់ ឬអាចជាពីព្រោះហេតុផលពលករខ្លួនឯងដែលធ្វើ ឲ្យខ្លួនមកធ្វើការវិញមុនពេលគ្រប់ 90ថ្ងៃ។ ប្រការនេះបានធ្វើឲ្យទារកត្រូវទទួលទានទឹកដោះ គោកំប៉ុងដែលជាផលិតផលសម្រេចជំនួសទឹកដោះម្តាយ។ ដូច្នេះដើម្បីជំរុញឲ្យទាំងនិយោជក និងពលករយកចិត្តទុកដាក់ចំពោះការចិញ្ចឹមទារកដោយទឹកដោះម្តាយ ទើបអគ្គនាយកដ្ឋាន សុខុមាលភាពនិងគ្រប់គ្រងពលករបានបង្កើតគម្រោងលើកស្ទួយទឹកដោះម្តាយក្នុងសហគ្រាស ដោយតម្រូវឲ្យនិយោជកដែលចូលរួមក្នុងគម្រោងរៀបចំសេវាសុខមាលភាព ដល់ពលករ ដូចជាផ្តល់ទឹកន្លែងដែលបិទជិតសមរម្យ មានតុ កៅអី អាងលាងដៃ ទូរទឹកកកសម្រាប់រក្សា ទុកទឹកដោះបំបៅទារក ព្រមទាំងសម្ភារៈបំបៅទារកផ្សេងទៀតដូចជា អាវបំបៅទារក ដបបំបៅទឹកដោះ ជាដើម។ គម្រោងខាងលើនេះតម្រូវឲ្យប្រើប្រាស់ថវិការមិនច្រើនទេ តែទទួលបានលទ្ធផលច្រើនស្របតាមគោលនយោបាយរបស់រដ្ឋាភិបាលដែលផ្តោតទៅលើការសន្សំសំចៃ និងប្រសិទ្ធភាពខ្ពស់។ ក្រៅពីនេះវាបានជួយកាត់បន្ថយចំណាយផ្សេងៗ ក្នុងការ ចិញ្ចឹមទារករបស់ពលករ ដូចជាការចំណាយលើទឹកដោះគោកំប៉ុង ។ ជាលទ្ធផលទារក អាចធំធាត់មានរាងកាយរឹងមាំ ប្រកបដោយសេក្តីស្រឡាញ់ ភាពកក់ក្តៅ និងភាពស្និទស្នាល រវាងម្តាយនិងកូន ព្រមទាំងជាសរសរទ្រូងរបស់ប្រទេសជាតិនៅថ្ងៃអនាគតខាងមុខ។ សរុបមក គម្រោងការនេះបានធ្វើឲ្យនិយោជក និងពលករយល់ពីសារសំខាន់ នៃការចញ្ចឹម ទារកដោយទឹកដោះម្តាយ ព្រមទាំងជំរុញឲ្យមានការរៀបចំទឹកន្លែងសម្រាប់បំបៅដោះ ទារកក្នុងសហគ្រាស៕